14

09.02.11

នស/រកម/០២១១/ ០០៤

ព្រះរាជក្រម
យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិង្ករាធរមហាក្សត្រ ខេមរាជនា សម្ភូហោតាស កម្ពុជឯករាជ្ជូបរណាសន្តិ សុតមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ៖

១. កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

២. កិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

៣. កិច្ចព្រមព្រៀង ស្តីពីយន្តការដោះស្រាយជម្លោះ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើ

១.កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

២.កិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

៣.កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយជម្លោះ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ដូចមានរាយនាមខាងក្រោម :

១-កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា ដែលបានចុះហត្ថលេខា នាថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៣ នៅទីក្រុងបាលី សាធារណរដ្ឋឥណ្ឌូនេស៊ី

២-កិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា ដែលបានចុះហត្ថលេខា នាថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ

៣-កិច្ចព្រមព្រៀង ស្តីពីយន្តការដោះស្រាយជម្លោះក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋ

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

តំណា ដែលបានចុះហត្ថលេខា នាថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងខាងលើនេះ ។

មាត្រា ៣ .-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆកអរ

នរោត្តម សីហមុនី

៣រស. ១១០២. ១៤០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមទ្បាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ:១៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០១១
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ឃុន ដិនកេន

3/3 ស

កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និង សាធារណរដ្ឋឥណ្ឌា

ឃុត្វាកថា

យើងប្រមុខរដ្ឋ/រដ្ឋាភិបាល នៃប្រទេសប្រុយណេដារ៉ូសាឡាំ ព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) សាធារណរដ្ឋឥណ្ឌូណេស៊ី (ឥណ្ឌូណេស៊ី) សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ឡាវ) ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា (មីយ៉ាន់ម៉ា) សាធារណរដ្ឋហ្វីលីពីន (ហ្វីលីពីន) សាធារណរដ្ឋសិង្ហបូរី (សិង្ហបូរី) ព្រះរាជាណាចក្រថៃឡង់ដ៍ (ថៃឡង់ដ៍) និង សាធារណរដ្ឋសង្គមនិយមវៀតណាម (វៀតណាម) បណ្តារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ជារួម អាស៊ាន ឬ បណ្តារដ្ឋសមាជិកអាស៊ាន ឬនីមួយៗរដ្ឋសមាជិកអាស៊ាន និង សាធារណរដ្ឋឥណ្ឌា (ឥណ្ឌា)។

ដោយនឹកឃើញថា នៅឆ្នាំ២០០២ យើងបានយល់ព្រមលើសារៈសំខាន់ នៃការបង្កើតកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជិតស្និទ្ធ និងធ្វើការឆ្ពោះទៅរកតំបន់ពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌា ជាទិសដៅយូរអង្វែង។

ដោយប្រាថ្នាអនុម័ត កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ (កិច្ចព្រមព្រៀងនេះ) រវាងអាស៊ាន និង ឥណ្ឌា (ជារួម បណ្តាភាគី ឬ នីមួយៗសំដៅទៅលើរដ្ឋសមាជិកអាស៊ាន ឬ ឥណ្ឌាជាភាគី) ដែលសំឡឹងទៅមុខដើម្បីរុញភាពជាដៃគូសេដ្ឋកិច្ចយ៉ាងជិតស្និទ្ធនៅក្នុងសតវត្សទី ២១

ដោយប្រាថ្នា ធ្វើឲ្យរបាំងមានកំរិតអប្បបរិមា និងចំណងសេដ្ឋកិច្ចកាន់តែខ្លាំងក្លាឡើង រវាងបណ្តាភាគីបន្ថយតម្លៃបង្កើន ពាណិជ្ជកម្ម និងវិនិយោគក្នុងតំបន់បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច បង្កើតទីផ្សារធំជាងប្រកបដោយឱកាសច្រើនជាង និងសេដ្ឋកិច្ចមាត្រដ្ឋានធំជាងសម្រាប់ធុរកិច្ច នៃបណ្តាភាគី និងបង្កើនភាពទាក់ទាញរបស់បណ្តាភាគីចំពោះមូលធន និងទេពកោសល្យ។

ការទទួលស្គាល់ តួនាទីដ៏សំខាន់ និងការរួមចំណែក នៃវិស័យធុរកិច្ចក្នុងការបង្កើនពាណិជ្ជកម្ម និងវិនិយោគរវាងបណ្តាភាគី និងការចាំបាច់ដើម្បីធ្វើឲ្យប្រសើរឡើង និងសម្រួលកិច្ចសហប្រតិបត្តិការ និងការប្រើប្រាស់នៃឱកាសធុរកិច្ចច្រើនជាង ដែលផ្តល់ឲ្យដោយតំបន់ពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌា។

ដោយទទួលស្គាល់ កំរិតខុសគ្នា នៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងចំណោមបណ្តារដ្ឋសមាជិកអាស៊ាន និងតម្រូវការភាពទន់ភ្លន់ រួមទាំងតម្រូវការដើម្បីសម្រួលការបង្កើន នៃការចូលរួមរបស់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម (បណ្តារដ្ឋសមាជិកអាស៊ានថ្មី) ក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាស៊ាន-ឥណ្ឌា និងការពង្រីកការនាំចេញរបស់ពួកគេក្នុងចំណោមនោះតាមរយៈការពង្រីកសមត្ថភាព ប្រសិទ្ធិភាព និងភាពប្រកួតប្រជែងក្នុងស្រុក

ដោយបញ្ជាក់ឡើងវិញ សិទ្ធិ កាតព្វកិច្ច និងកិច្ចការនៃភាគីនីមួយៗក្រោមអង្គការពាណិជ្ជកម្ម ពិភពលោក (WTO) និងកិច្ចព្រមព្រៀង និងកិច្ចសម្រុះសម្រួលពហុភាគីតំបន់ និងទ្វេភាគីផ្សេងទៀត

ដោយទទួលស្គាល់ថា កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ អាចផ្តល់រួមចំណែកបង្កើនល្បឿន សេរីកម្មតំបន់ និងពិភពលោក និងជាមូលដ្ឋានគ្រឹះសម្រាប់ក្របខ័ណ្ឌ នៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី

ឯានយល់ព្រមដូចតទៅ :

មាត្រា ១

គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺ :

(ក) ពង្រឹង និងបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្ម និងវិនិយោគរវាងបណ្តាភាគី

(ខ)ធ្វើសេរីកម្មជាបណ្តើរៗ និងជម្រុញពាណិជ្ជកម្មទំនិញ និងសេវាព្រមទាំងបង្កើតរបបវិនិយោគដែលងាយស្រួលសេរី និង មានតម្លាភាព

(គ) ស្វែងរកវិស័យថ្មីៗ និងរៀបចំវិធានសមស្របសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជិតស្និទ្ធរវាងភាគីទាំងឡាយ និង

(ឃ) សម្រួលសមាហរណកម្មសេដ្ឋកិច្ចឲ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់ របស់រដ្ឋសមាជិកអាស៊ានថ្មី និងបន្តយកគំលាតការអភិវឌ្ឍក្នុងចំណោមភាគីទាំងឡាយ។

មាត្រា ២

ខ្ចាន់ការទាំងឡាយសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

បណ្តាភាគីឯកភាពចូលរួមក្នុងការចរចា ដើម្បីបង្កើតតំបន់ពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌា ដែលរាប់បញ្ចូលទាំងតំបន់ពាណិជ្ជកម្មសេរីទំនិញ សេវា និងវិនិយោគ និងដើម្បីពង្រឹង និងបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតាមរយៈវិធីដូចតទៅ :

(ក) ការលុបបំបាត់ជាបណ្តើរៗនៃអត្រាពន្ធ និងរបាំងមិនមែនពន្ធក្នុងពាណិជ្ជកម្មទំនិញចាំបាច់ស្ទើរតែទាំងអស់

(ខ) សេរីកម្មជាបណ្តើរៗ នៃពាណិជ្ជកម្មសេវាលើវិស័យជាច្រើន

(ក) ការបង្កើតវេទិកាពាណិជ្ជកម្ម និងវិនិយោគប្រកួតប្រជែង និងសៀវភៅណែនាំ ដែលសម្រួល និងធ្វើឲ្យប្រសើរដល់តំបន់-វិនិយោគនៅតំបន់ពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌា

(ខ) ការផ្តល់ប្រព្រឹត្តកម្មដោយឡែក និងពិសេសដល់បណ្តារដ្ឋសមាជិកអាស៊ានថ្មី

(គ) ការផ្តល់ភាពទន់ភ្លន់ដល់បណ្តាភាគីក្នុងការចរចា និងតំបន់ពាណិជ្ជកម្ម និងវិនិយោគ អាស៊ាន-ឥណ្ឌា ដើម្បីដោះស្រាយវេទយិតភាពរបស់ពួកគេនៅក្នុងវិស័យទំនិញ សេវា និង វិស័យវិនិយោគ។ ភាពទន់ភ្លន់នោះនឹងត្រូវចរចា និងឯកភាពគ្នាទៅវិញទៅមកដោយឈរលើ គោលការណ៍បដិការ និងផលចំណេញទៅវិញទៅមក

(ឃ) ការបង្កើតវិធានការសម្រួលវិនិយោគ និងពាណិជ្ជកម្មប្រកបដោយប្រសិទ្ធិភាព រួមទាំង មិនត្រឹមការធ្វើឲ្យងាយស្រួលនីតិវិធីគយ និងការរៀបចំកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញ ទៅមក

(ង) ការពង្រីកនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុងវិស័យ ដែលអាចឯកភាពគ្នាទៅវិញទៅ-មកវាងបណ្តាភាគី ដែលនឹងមានការបំពេញឲ្យជម្រុញថែមទៀតទំនាក់ទំនងពាណិជ្ជកម្ម និង វិនិយោគវាងបណ្តាភាគី និងការរៀបចំផែនការសកម្មភាព និងកម្មវិធីដើម្បីអនុវត្តវិស័យផ្នែក សហប្រតិបត្តិការដែលបានឯកភាព និង

(ច) ការបង្កើតយន្តការសមស្របក្នុងគោលបំណងអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នៃកិច្ច ព្រមព្រៀងនេះ។

មាត្រា ៣

ពាណិជ្ជកម្មទំនិញ

(១) ក្នុងទស្សនៈពន្លឿនការពង្រីកពាណិជ្ជកម្មទំនិញ បណ្តាភាគីឯកភាពចូលរួមការចរចា ដែលក្នុងនោះពន្ធ និងបទប្បញ្ញត្តិរឹតត្បិតនានា នៃពាណិជ្ជកម្ម (លើកលែងនៅពេលចាំបាច់តែបទប្បញ្ញត្តិ ដែលបានអនុញ្ញាតនៅក្រោមមាត្រា XXIV(8)(b) នៃកិច្ចព្រមព្រៀងទូទៅ WTO ស្តីពីពន្ធគយ និង ពាណិជ្ជកម្ម (GATT) និងត្រូវលុបបំបាត់លើពាណិជ្ជកម្មទំនិញស្ទើរតែទាំងអស់រវាងបណ្តាភាគី។

(២) សម្រាប់គោលបំណងនៃមាត្រានេះ និយមន័យតទៅនេះនឹងអនុវត្ត លើកលែងតែបរិបទតម្រូវផ្សេងពីនេះ :

(ក) អត្រាពន្ធអនុវត្ត (MFN) ប្រជាជាតិអនុគ្រោះបំផុតយោងទៅលើអត្រាពន្ធអនុវត្តន៍រៀងៗ ខ្លួននៃបណ្តាភាគី នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ និង

(ខ) វិធានមិនមែនពន្ធនឹងរាប់បញ្ចូលទាំងរបាំងមិនមែនពន្ធ។

(៣) នៅពេលចុះហត្ថលេខាកិច្ចព្រមព្រៀងនេះ បណ្តាភាគីនឹងចាប់ផ្តើមការពិគ្រោះយោបល់ ទៅលើរបបពាណិជ្ជកម្មទៅវិញទៅមក រាប់បញ្ចូលទាំងតែមិនបានកំណត់ត្រឹមដូចតទៅ :

(ក) ពាណិជ្ជកម្ម និងស្ថិតិពន្ធ

(ខ) នីតិវិធីគយ វិធាន និងបទប្បញ្ញត្តិ

(គ) វិធានមិនមែនពន្ធរាប់បញ្ចូលទាំង តែមិនកំណត់ត្រឹម តម្រូវការអាជ្ញាប័ណ្ណនាំចូល និង នីតិវិធីការរឹតត្បិតលើបរិមាណរបាំងបច្ចេកទេសពាណិជ្ជកម្មអនាម័យ និងភូតាមអនាម័យ

(ឃ) បទប្បញ្ញត្តិ និងវិធានកម្មសិទ្ធិបញ្ញា និង

(ង) នយោបាយពាណិជ្ជកម្ម។

(៤) កម្មវិធីកាត់បន្ថយ ឬ លុបបំបាត់ពន្ធ នៃបណ្តាភាគីនឹងតម្រូវឲ្យអត្រាពន្ធលើបញ្ជីទំនិញកាត់បន្ថយជាបណ្តើរៗ និងបើអាចធ្វើទៅបានលុបបំបាត់អនុលោមទៅតាមមាត្រានេះ។

(៥) ផលិតផលដែលជាកម្មវត្ថុ នៃកម្មវិធីលុបបំបាត់ និងកាត់បន្ថយអត្រាពន្ធក្រោមមាត្រានេះ នឹងរាប់បញ្ចូលផលិតផលទាំងអស់តែមិនគ្របដណ្តប់ដោយកម្មវិធីប្រមូលផលដើមដៃ ក្រោមមាត្រា ៧ នៃកិច្ចព្រមព្រៀងនេះ ហើយផលិតផលទាំងនោះនឹងត្រូវចាត់ថ្នាក់ជាពីរផ្លូវដូចតទៅ :

(ក) ផ្លូវធម្មតា

ផលិតផលដាក់នៅក្នុងបញ្ជីផ្លូវធម្មតាដោយភាគី និងដោយខ្លួនឯងនឹងត្រូវកាត់បន្ថយ ឬ លុបជាបណ្តើរៗ នូវអត្រាពន្ធអនុវត្ត MFN ស្របតាមអត្រាពន្ធ និងកម្មវិធីដែលបានចែង (ដែលត្រូវឯកភាពទៅ-វិញទៅមកដោយបណ្តាភាគី) ក្នុងរយៈពេលពី :

(i) ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ សម្រាប់ប្រទេសប្រ៊ុយ-ណេដារ៉ាសាឡាំ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សឹង្ហបូរី និង ថៃឡង់ដ៍ និង ឥណ្ឌា

(ii) ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ សម្រាប់ប្រទេសហ្វីលីពីន និង ឥណ្ឌា

(iii) ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ សម្រាប់ប្រទេសឥណ្ឌា និងថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ សម្រាប់រដ្ឋសមាជិកអាស៊ានថ្មី។ ចំពោះអត្រាពន្ធដែលត្រូវបានកាត់បន្ថយ តែមិនត្រូវបានលុបបំបាត់អត្រាពន្ធនោះ នឹងត្រូវលុបបំបាត់ជាបណ្តើរៗ ក្នុងរយៈពេលដែលនឹងត្រូវឯកភាពគ្នាទៅវិញទៅមករវាងបណ្តាភាគី។

(ខ) ផ្លូវរសើប

(i) ចំនួនផលិតផលដាក់នៅក្នុងបញ្ជីផ្លូវរសើបនឹងកំរិតជាអតិបរិមា ដោយការឯកភាពគ្នាទៅវិញទៅមកក្នុងចំណោមបណ្តាភាគី

(ii) ផលិតផលដាក់នៅក្នុងបញ្ជីផ្លូវរសើបដោយភាគី និងដោយខ្លួនឯងនឹងត្រូវកាត់បន្ថយ ឬ លុបបំបាត់ជាបណ្តើរៗនូវអត្រាពន្ធអនុវត្ត MFN រៀងៗខ្លួន នៅក្នុងរយៈពេលដែលត្រូវឯកភាពគ្នាទៅវិញទៅមករវាងបណ្តាភាគី។

(៦) ការសន្យាដោយបណ្តាភាគីនៅក្រោមមាត្រានេះ និងមាត្រា ៧ នៃកិច្ចព្រមព្រៀងនេះត្រូវបំពេញតាមតម្រូវការរបស់ WTO ដើម្បីលុបបំបាត់អត្រាពន្ធ លើពាណិជ្ជកម្មស្ទើរទាំងអស់រវាងបណ្តាភាគី។

(ល) អត្រាពន្ធអនុគ្រោះដែលបានចែង និងដែលត្រូវឯកភាពគ្នាទៅវិញទៅមកវាងបណ្តាភាគី អនុលោមតាមមាត្រានេះ នឹងកំណត់ត្រឹមតែព្រំដែន នៃអត្រាពន្ធអនុគ្រោះ ឬ រង្វង់នៃឆ្នាំអនុវត្តដែលបានចែងដោយបណ្តាភាគី។

(ផ) ការចរចារវាងបណ្តាភាគី ដើម្បីបង្កើតតំបន់ពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌា ដែលគ្របដណ្តប់ពាណិជ្ជកម្មទំនិញនឹងត្រូវបូកបញ្ចូល តែមិនបានកំណត់ត្រឹមដូចតទៅ :

(ក) រយៀបនានារាប់បញ្ចូលទាំងវិធានណែនាំការលុបបំបាត់ និង/ឬ ការកាត់បន្ថយពន្ធនាំចូល

(ខ) វិធានដើមកំណើតទំនិញ

(គ) ប្រព្រឹត្តកម្មនៃអត្រាពន្ធក្រៅកូតា (out-of-quota rate)

(ឃ) ការកែប្រែនៃការសន្យារបស់ភាគីមួយក្រោមកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញដោយផ្អែកទៅលើកិច្ចព្រមព្រៀង WTO

(ង) របាំង/វិធានមិនមែនពន្ធរាប់បញ្ចូល តែមិនកំណត់ត្រឹមការរឹតត្បិតលើបរិមាណ ឬការហាមឃាត់លើការនាំចូល នៃផលិតផលណាមួយ ឬ លើការនាំចេញ ឬ លក់សម្រាប់ការនាំចេញ នៃផលិតផលណាមួយព្រមទាំងវិធានការអនាម័យ និងភូតាមអនាម័យ និងរបាំងបច្ចេកទេសពាណិជ្ជកម្ម

(ច) ការការពារទាំងឡាយ ដោយផ្អែកលើកិច្ចព្រមព្រៀង WTO

(ឆ) វិន័យស្តីពីឧបត្ថម្ភធន និងវិធានការតបត និងវិធានការប្រឆាំងការបង្ខូចតម្លៃ ដោយផ្អែកទៅលើកិច្ចព្រមព្រៀង WTO ដែលមាន និង

(ជ) ការសម្រួល និងការធ្វើឲ្យប្រសើរឡើងការការពារពេញលេញ និងប្រកបដោយប្រសិទ្ធិភាពនូវទិដ្ឋភាពពាណិជ្ជកម្ម នៃកម្មសិទ្ធិបញ្ញាដោយផ្អែកលើកិច្ចព្រមព្រៀង WTO អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលមានស្រាប់ និងកិច្ចព្រមព្រៀងទាក់ទងដទៃទៀត។

មាត្រា ៤

ពាណិជ្ជកម្មសេវា

ក្នុងទស្សនៈពន្លឿនការពង្រីកពាណិជ្ជកម្មសេវា បណ្តាភាគីឯកភាពចូលរួមការចរចា ដើម្បីធ្វើសេរីកម្មជាបណ្តើរៗ ពាណិជ្ជកម្មសេវាផ្អែកលើមូលដ្ឋានអនុគ្រោះ ដោយគ្របដណ្តប់លើវិស័យច្រើន។ ការចរចានេះនឹងត្រូវឆ្ពោះទៅរក :

(ក) ការលុបបំបាត់ជាបណ្តើរៗ នៃការរើសអើងស្ទើរតែទាំងអស់រវាង ឬ ក្នុងចំណោមបណ្តាភាគី និង/ឬ ការហាមឃាត់នៃវិធានការរើសអើងថ្មី ឬ បន្ថែមចំពោះពាណិជ្ជកម្មសេវារវាងបណ្តាភាគី លើកលែងតែនៃការដែលបានអនុញ្ញាតនៅក្រោមមាត្រា V(1)(b) នៃកិច្ចព្រមព្រៀងទូទៅ WTO ស្តីពីពាណិជ្ជកម្មសេវា (GATTS)

(ខ) ការពង្រីកជម្រុះ និងវិសាលភាពនៃសេរីកម្មពាណិជ្ជកម្មសេវាលើសពីអ្វី ដែលបានធ្វើដោយរដ្ឋសមាជិកអាស៊ាន និង ឥណ្ឌា នៅក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវា (GATTS) និង

(គ) កិច្ចសហប្រតិបត្តិការកាន់តែប្រសើរក្នុងសេវារវាងបណ្តាភាគី ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធិភាព និងភាពប្រកួតប្រជែងព្រមទាំងការបំបែកការផ្គត់ផ្គង់ និងការចែកចាយសេវារបស់អ្នកផ្គត់ផ្គង់សេវារៀងៗខ្លួន នៃបណ្តាភាគី។

មាត្រា ៥
ការវនិយោគ

ដើម្បីជម្រុញការវិនិយោគ និងបង្កើតរបបវិនិយោគ ដែលសើរឆាយស្រួលមានតម្លាភាព និងប្រកួតប្រជែងបណ្តាភាគីឯកភាព :

(ក) ចូលរួមចរចា ដើម្បីធ្វើសេរីកម្មជាបណ្តើរៗ នូវរបបវិនិយោគរបស់ខ្លួន

(ខ) ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការវិនិយោគ សម្រួលការវិនិយោគ និងធ្វើឲ្យប្រសើរតម្លាភាពវិធាន និងបទប្បញ្ញត្តិវិនិយោគ និង

(គ) ផ្តល់ការគ្រារពារដល់វិនិយោគ។

មាត្រា ៦
វិស័យនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

(១) តាមការសមស្របបណ្តាភាគីឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួន នៅក្នុងវិស័យដូចតទៅតែមិនកំណត់ត្រឹម :

(ក) ការសម្រួលពាណិជ្ជកម្ម

(i) កិច្ចសម្របសម្រួលទទួលស្គាល់គ្នាទៅវិញទៅមកការវាយតម្លៃអនុលោមភាពនីតិវិធី នៃការចុះបញ្ជី និងបទប្បញ្ញត្តិបច្ចេកទេស និងស្តង់ដារ

(ii) វិធានការមិនមែនពន្ធ

(iii) កិច្ចសហប្រតិបត្តិការគយ

(iv) ហិរញ្ញប្បទានពាណិជ្ជកម្ម និង

(v) ការសម្រួលទិដ្ឋាការជំនួញ និងការធ្វើដំណើរ។

(ខ) វិស័យនៃកិច្ចសហប្រតិបត្តិការ :

(i) កសិកម្ម នេសាទ និងព្រៃឈើ

(ii) សេវាកម្ម ប្រព័ន្ធផ្សព្វផ្សាយ និងកំសាន្ត សុខភាព ហិរញ្ញវត្ថុ ទេសចរណ៍ សំណង់ ការនាំចូល របៀបធ្វើជំនួញ បរិស្ថាន

(iii) ព័ែ និងថាមពល : ប្រេង និងឧស្ម័នធម្មជាតិ ការផលិតថាមពល និងការផ្គត់ផ្គង់

(iv) វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា : បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ពាណិជ្ជកម្ម អេឡិកត្រូនិក ជីវៈបច្ចេកវិទ្យា

(v) ការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ : ការដឹកជញ្ជូន និងគមនាគមន៍

(vi) កម្មន្តសាល : រថយន្ត ឱសថ វាយនភ័ណ្ឌ វត្ថុធាតុគីមីពីប្រេងកាត សំលៀកបំពាក់ ការកែច្នៃអាហារ ផលិតផលស្បែក ផលិតផលគ្រឿងចក្រធុន-ស្រាល និងការកែច្នៃត្បូង និងគ្រឿងអលង្ការ

(vii) ការអភិវឌ្ឍធនធានមនុស្ស : ការកសាងសមត្ថភាព ការអប់រំ ការផ្ទេរបច្ចេកវិទ្យា និង

(viii) ផ្សេងៗ : សិប្បកម្ម សហគ្រាសធុនតូច និងមធ្យម នយោបាយប្រកួតប្រជែង ការអភិវឌ្ឍអាងទន្លេមេគង្គ សិទ្ធិកម្មសិទ្ធបញ្ញា សិទ្ធកម្មសាធារណៈ។

(គ) ការជម្រុញពាណិជ្ជកម្ម និងវិនិយោគ :

(i) ពិព័ណ និងការតាំងបង្ហាញ

(ii) ការភ្ជាប់បណ្តាញអាស៊ាន-ឥណ្ឌា និង

(iii) ដៃគូវិស័យធុរៈកិច្ច។

(២) បណ្តាភាគីឯកភាពអនុវត្តកម្មវិធីកសាងសមត្ថភាព និងជំនួយបច្ចេកទេស ជាពិសេសសម្រាប់រដ្ឋសមាជិកអាស៊ានថ្មី ដើម្បីកែតម្រូវរចនាសម្ព័ន្ធសេដ្ឋកិច្ច និងពង្រីកពាណិជ្ជកម្ម និងវិនិយោគរបស់ខ្លួនជាមួយឥណ្ឌា។

(៣) បណ្តាភាគីអាចបង្កើតអង្គភាពដទៃទៀតបើចាំបាច់ ដើម្បីសម្របសម្រួល និងអនុវត្តសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ចណាមួយស្របតាមកិច្ចព្រមព្រៀងនេះ។

មាត្រា ៧
កម្មវិធីប្រមូលផលដើមដៃ

(១) ក្នុងទស្សនៈពន្លឿនការអនុវត្ត នៃកិច្ចព្រមព្រៀងនេះ បណ្តាភាគីឯកភាពអនុវត្តកម្មវិធីប្រមូលផលដើមដៃដែលជាផ្នែកមួយ នៃកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌា សម្រាប់បណ្តាផលិតផលនៅក្នុងកថាខ័ណ្ឌ ៣ (ក) ខាងក្រោម។ ការកាត់បន្ថយអត្រាពន្ធជាបណ្តើរៗ នៅក្រោមកម្មវិធីប្រមូលផលដើមដៃនឹងចាប់ផ្តើមពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៨ និងការលុបបំបាត់អត្រាពន្ធត្រូវបញ្ចប់នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៧ សម្រាប់អាស៊ាន ៦ និង ឥណ្ឌា និងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១០ សម្រាប់រដ្ឋសមាជិកអាស៊ានថ្មី។

(២) សម្រាប់គោលបំណងនៃមាត្រានេះ និងនិយមន័យតទៅនេះនឹងត្រូវអនុវត្ត លើកលែងតែបរិបទតម្រូវផ្សេងពីនេះ :

(ក) អាស៊ាន ៦ សំដៅទៅលើប្រទេសប្រ៊ុយណេដារ៉ូសាឡឹម ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបូរី និង ថៃឡង់ដ៍ និង

(ខ) អត្រាពន្ធអនុវត្ត MFN សំដៅទៅលើអត្រាអនុវត្តន៍រៀងៗខ្លួនរបស់បណ្តាភាគីនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤។

(៣) វិសាលភាពនៃផលិតផល ការលុបបំបាត់ និងការកាត់បន្ថយអត្រាពន្ធ ការបំបាត់រាំងមិនមែនពន្ធ វិធានដើមកំណើតទំនិញ មធ្យោបាយដោះស្រាយពាណិជ្ជកម្ម និងវិធានការបន្ទាន់ដែលអាចអនុវត្តទៅលើកម្មវិធីប្រមូលផលដើមដៃ គឺដូចតទៅ :

(ក) វិសាលភាពនៃផលិតផល

(i) ផលិតផលរួម ដែលបណ្តាភាគីឯកភាពផ្លាស់ប្តូរសម្បទានអត្រាពន្ធមានដាក់នៅក្នុងឧបសម្ព័ន្ធ ក

(ii) ផលិតផល ដែលឥណ្ឌាយល់ព្រមផ្តល់សម្បទានទៅរដ្ឋសមាជិកអាស៊ានថ្មីមានដាក់នៅក្នុងឧបសម្ព័ន្ធ ខ។

(ខ) របៀបសម្រាប់ការកាត់បន្ថយ និងលុបបំបាត់ពន្ធរបៀប សម្រាប់ផលិតផលគ្របដណ្តប់ដោយកម្មវិធីប្រមូលផលដើមដៃ នឹងត្រូវបញ្ចប់នៅក្រោមមាត្រា ៨(២) នៃកិច្ចព្រមព្រៀងនេះ ។

(គ) ការបំបាត់វិធានមិនមែនពន្ធ ដើម្បីសម្រេចពេញលេញផលចំណេញយ៉ាងច្រើនពីកម្មវិធីប្រមូលផលដើមដៃ បណ្តាភាគីត្រូវជម្រុញ និងសម្រួលពាណិជ្ជកម្មផលិតផលទាំងអស់បានដាក់នៅក្នុងកម្មវិធីប្រមូលផលដើមដៃ។ បណ្តាភាគីនឹងខិតខំផងដែរផ្អាកការប្រើប្រាស់វិធានការមិនមែនពន្ធ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ពាណិជ្ជកម្ម នៃផលិតផលប្រមូលផលដើមដៃ។

(ឃ) វិធានដើមកំណើតទំនិញផលិតផល ក្នុងកម្មវិធីប្រមូលផលដើមដៃ នឹងមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលអត្រាពន្ធអនុគ្រោះ ស្របទៅតាមវិធានដើមកំណើតទំនិញ ដែលត្រូវបានឯកភាពនៅក្រោមមាត្រា ៨(២) នៃកិច្ចព្រមព្រៀងនេះ។

(ង) ការអនុវត្តនៃបទប្បញ្ញត្តិ WTO : បទប្បញ្ញត្តិ WTO ដែលណែនាំការកែប្រែការសន្យាសកម្មភាពការការពារវិធានការបន្ទាន់ និងដំណោះស្រាយពាណិជ្ជកម្មដទៃទៀត រួមទាំងការប្រឆាំងការបង្ខូចតម្លៃ និងឧបត្ថម្ភធន និងវិធានការតបត ក្នុងរយៈពេលបណ្តោះអាសន្ន និងត្រូវអនុវត្តលើផលិតផល នៃកម្មវិធីប្រមូលផលដើមដៃ ហើយនឹងត្រូវជំនួសដោយវិន័យពាក់ព័ន្ធ ដែលត្រូវចរចា និងឯកភាពដោយបណ្តាភាគីក្រោមមាត្រា ៣ (៨) នៃកិច្ចព្រមព្រៀងនេះនៅពេលដែលវិន័យនោះត្រូវបានអនុវត្ត។

(៤) ភាគីទាំងអស់នឹងស្វែងរកផល ដែលភាពអាចធ្វើទៅបាន នៃកិច្ចសហប្រតិបត្តិការក្នុងវិស័យរៀបរាប់ក្នុងឧបសម្ព័ន្ធ គ។

មាត្រា ៨

រយៈពេល

(១) សម្រាប់ពាណិជ្ជកម្មទំនិញ ការចរចាទៅលើកិច្ចព្រមព្រៀងសម្រាប់ការកាត់បន្ថយ/លុបបំបាត់ពន្ធ និងបញ្ហាផ្សេងៗទៀតដូចមានចែងនៅក្នុងមាត្រា ៣ នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវចាប់ផ្តើម

នៅក្នុងខែមករា ឆ្នាំ២០០៤ ហើយនឹងត្រូវបញ្ចប់នៅថ្ងៃ៣០ ខែកុម្ភៈ ឆ្នាំ២០០៥ ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា។

(២) ការចរចាស្តីពីវិធានដើមកំណើតទំនិញ សម្រាប់ពេលិជ្ជកម្មទំនិញក្រោមមាត្រា ៣ និង ៧ និងរបៀបកាត់បន្ថយ និងលុបបំបាត់ពន្ធក្រោមមាត្រា ៧ នឹងត្រូវបញ្ចប់មិនយឺតជាង ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៤។

(៣) សម្រាប់ពាណិជ្ជកម្មសេវា និងវិនិយោគ ការចរចាលើកិច្ចព្រមព្រៀងនីមួយៗ នឹងចាប់ផ្តើមនៅឆ្នាំ២០០៥ ហើយនឹងបញ្ចប់នៅឆ្នាំ២០០៧។ ការសំគាល់សេរីកម្មលើ នៃវិស័យសេវា និងវិនិយោគ នឹងបញ្ចប់សម្រាប់ការអនុវត្តជាបន្ទាន់ស្របទៅតាមរយៈពេល ដែលត្រូវឯកភាពទៅវិញទៅមក :

(ក) ដោយពិនិត្យ ពិចារណាទៅលើវិស័យផ្សេងៗនៃបណ្តាភាគី និង

(ខ) ជាមួយនឹងប្រព្រឹត្តកម្មពិសេស និងដោយឡែក និងភាពទន់ភ្លន់សម្រាប់ប្រទេសមាជិកអាស៊ានថ្មី។

(៤) សម្រាប់វិស័យដទៃទៀត នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច បណ្តាភាគីនឹងបង្កើតឬស្ថាបនាដែនលើកម្មវិធីដែលមានស្រាប់ និងឯកភាពដូចមានចែងនៅក្នុងមាត្រា ៦ នៃកិច្ចព្រមព្រៀងនេះ រៀបចំកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចថ្មី ហើយបញ្ចប់កិច្ចព្រមព្រៀងស្តីពីវិស័យផ្សេងៗទៀត នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។ បណ្តាភាគីនឹងធ្វើរបៀបនេះយ៉ាងរួសរាន់ផងដែរ សម្រាប់ការអនុវត្តតាមរបៀប និង ល្បឿនអាចទទួលយកបានសម្រាប់ភាគីពាក់ព័ន្ធទាំងអស់។ កិច្ចព្រមព្រៀងនឹងបង្ហូលរយៈពេលសម្រាប់ការអនុវត្តការសន្យា ដែលមាននៅក្នុងនោះ។

មាត្រា ៩

ប្រព្រឹត្តកម្មប្រជាជាតិអនុគ្រោះបំផុត

ភាគីឥណ្ឌា នឹងបន្តផ្តល់ប្រព្រឹត្តកម្មប្រជាជាតិអនុគ្រោះបំផុតស្របតាមវិធាន និងវិន័យ នៃ WTO ទៅដល់រដ្ឋសមាជិកអាស៊ានទាំងអស់ ដែលមិនមែនសមាជិក WTO នាថ្ងៃចុះហត្ថលេខា នៃកិច្ចព្រមព្រៀងនេះ។

មាត្រា ១០

ការលើកលែងជាទូទៅ

ក្រោមលក្ខខណ្ឌតម្រូវ ដែលវិធានការនោះមិនបានអនុវត្តតាមរបៀប ដែលអាចជាមធ្យោបាយរើសអើងមិនដោះសារបាន ឬ ដោយបំពានរវាងក្នុងចំណោមបណ្តាភាគី ដែលលក្ខខណ្ឌដូចគ្នាមានជាទូទៅ ឬ ការរឹតត្បិតទៅលើពាណិជ្ជកម្មនៅក្នុងពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះនឹងរារាំងភាគីណាមួយធ្វើសកម្មភាព និងអនុម័តវិធានការសម្រាប់ការពារសន្តិសុខជាតិ ឬ ការការពារនៃវត្ថុ ដែលមានតម្លៃចិត្រសិល្បៈ ប្រវត្តិសាស្ត្រ បុរាណវិទ្យា ឬ វិធានការដទៃទៀតដែលចាំបាច់សម្រាប់ការពារសីលធម៌សាធារណៈ ឬ សម្រាប់ការពារសុខភាព ជីវិតមនុស្ស សត្វ ឬ រុក្ខជាតិ និងការអភិរក្សនៃធនធានធម្មជាតិ ដែលអាចរិចរិលអស់។

មាត្រា ១១

យន្តការដោះស្រាយវិវាទ

(១) នៅក្នុងរយៈពេលមួយ (១) ឆ្នាំបន្ទាប់ពីថ្ងៃចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ បណ្តាភាគីនឹងបង្កើតយន្តការ និងនីតិវិធីដោះស្រាយវិវាទជាផ្លូវការសមស្រប សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ។

(២) នៅពេលរងចាំការបង្កើតនៃយន្តការ និងនីតិវិធីនៃការដោះស្រាយវិវាទជាផ្លូវការក្រោមកថាខ័ណ្ឌ ១ ខាងលើជម្លោះណាក៏ដោយពាក់ព័ន្ធទៅនឹងការបកស្រាយ ឬ ការអនុវត្តនៃកិច្ចព្រមព្រៀងនេះ នឹងត្រូវបានដោះស្រាយដោយមិត្តភាពតាមរយៈការពិគ្រោះយោបល់គ្នាទៅវិញទៅមក។

មាត្រា ១២

ការរៀបចំស្ថាប័នសម្រាប់ការចរចា

(១) គណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា នឹងត្រូវបង្កើតឡើង ដើម្បីអនុវត្តកម្មវិធីនៃការចរចាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។

(២) គណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា អាចអញ្ជើញមន្ត្រីជំនាញ ឬ បង្កើតក្រុមការងារណាមួយចាំបាច់ ដើម្បីជួយក្នុងការចរចាលើវិស័យទាំងអស់នៅក្នុងតំបន់ពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌា។

(៣) គណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា នឹងរាយការណ៍ដោយទៀងទាត់ទៅរដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌា និងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (ការពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ឥណ្ឌា) តាមរយៈកិច្ចប្រជុំនៃឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ឥណ្ឌា ស្តីពីដំណើរការ និងលទ្ធផលនៃការចរចារបស់ខ្លួន។

(៤) ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មរដ្ឋាភិបាលឥណ្ឌា និងលេខាធិការដ្ឋានអាស៊ាន នឹងរួមគ្នាផ្តល់នូវការគាំទ្រលេខាធិការដ្ឋានរបស់គណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ឥណ្ឌានៅពេលណា ឬ កន្លែងណាការចរចានោះដំណើរការ។

មាត្រា ១៣

បទប្បញ្ញត្តិផ្សេងៗ

(១) កិច្ចព្រមព្រៀងនេះមានឧបសម្ព័ន្ធ និងមាតិការ និងរាល់ឧបករណ៍ច្បាប់ដែលបានឯកភាពនាពេលខាងមុខអនុលោមតាមកិច្ចព្រមព្រៀងនេះ។

(២) លើកលែងតែមានចែងផ្សេង នៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងនេះ ឬ សកម្មភាពណាមួយដែលចាត់ក្រោមកិច្ចព្រមព្រៀងនេះ នឹងមិនប៉ះពាល់ ឬ មោយៈនូវសិទ្ធិ និងកាតព្វកិច្ច នៃភាគីក្រោមកិច្ចព្រមព្រៀង ដែលមានស្រាប់ដែលភាគីនោះចូលរួម។

(៣) បណ្តាភាគីនឹងខិតខំទប់ស្កាត់ពីការបង្កើតការរើតត្បិត ឬ ការកំណត់ដែលអាចប៉ះពាល់ការអនុវត្តកិច្ចព្រមព្រៀងនេះ។

ដើម្បីជាសាក្ខីភាព យើងបានហត្ថលេខាកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទ្វេទ្វាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋឥណ្ឌានេះ។

ធ្វើនៅទីក្រុងបាលី នាថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៣ ជាពីរច្បាប់ជាភាសាអង់គ្លេស។

សម្រាប់ប្រ៊ុយណេដារ៉ូសាឡាំ ហត្ថលេខា ហាហ្សឺ ហាសានណាល បូលគ្យាហ ស្តេចនៃប្រ៊ុយណេដារ៉ូសាឡាំ	សម្រាប់សាធារណរដ្ឋឥណ្ឌា ហត្ថលេខា អាតាល បីហារី វ៉ាជ្បាយ នាយករដ្ឋមន្ត្រី
សម្រាប់ព្រះរាជាណាចក្រកម្ពុជា ហត្ថលេខា សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី	
សម្រាប់សាធារណរដ្ឋឥណ្ឌូណេស៊ី ហត្ថលេខា មេហ្គាវ៉ាទី ស៊ូកាណូពុទ្រី ប្រធានាធិបតេយ្យ	
សម្រាប់សាធារណរដ្ឋប្រជាធិបតេយ្យប្រមានិតឡាវ ហត្ថលេខា ប៊ុនហាង វ៉ូរ៉ាជិត នាយករដ្ឋមន្ត្រី	
សម្រាប់ម៉ាឡេស៊ី ហត្ថលេខា	

បណ្ឌិត មហាធៀ ប៊ី មហាមែត នយករដ្ឋមន្ត្រី	
សម្រាប់សហភាពមីយ៉ាន់ម៉ា ហត្ថលេខា ឧត្តមសេនីយ៍ ឃិន នីយុន នាយករដ្ឋមន្ត្រី	
សម្រាប់សាធារណរដ្ឋហ្វីលីពីន ហត្ថលេខា គ្លូរីយ៉ូ មាកាប៉ាំង្គាល អារ៉ីយ៉ូ ប្រធានាធិបតេយ្យ	
សម្រាប់សាធារណរដ្ឋសឹង្ហបូរី ហត្ថលេខា ហ្គូចុក តុង នាយករដ្ឋមន្ត្រី	
សម្រាប់ព្រះរាជាណាចក្រថៃឡង់ដ៍ ហត្ថលេខា បណ្ឌិត ថាកស៊ីន ស៊ីណាវ៉ាត្រា នាយករដ្ឋមន្ត្រី	

សម្រាប់សាធារណរដ្ឋសង្គមនិយមវៀតណាម ហត្ថលេខា ជាន់ ភ័ន ខៃ នាយករដ្ឋមន្ត្រី	

Framework Agreement on Comprehensive Economic Cooperation Between the Republic of India and the Association of Southeast Asian Nations

PREAMBLE

WE, the Heads of State/Government of Brunei Darussalam, the Kingdom of Cambodia (Cambodia), the Republic of Indonesia (Indonesia), the Lao People's Democratic Republic (Lao PDR), Malaysia, the Union of Myanmar (Myanmar), the Republic of the Philippines (the Philippines), the Republic of Singapore (Singapore), the Kingdom of Thailand (Thailand) and the Socialist Republic of Viet Nam (Viet Nam), Member States of the Association of Southeast Asian Nations (collectively, "ASEAN" or "ASEAN Member States", or individually, "ASEAN Member State"), and the Republic of India (India);

RECALLING that in 2002, we had agreed on the importance of enhancing our close economic cooperation and to work towards an ASEAN-India Regional Trade and Investment Area (RTIA) as a long-term objective;

DESIRING to adopt a Framework Agreement on Comprehensive Economic Cooperation (this Agreement) between ASEAN and India (collectively, "the Parties", or individually referring to an ASEAN Member State or to India as a "Party") that is forward-looking in order to forge a closer economic partnership in the 21st century;

DESIRING to minimise barriers and deepen economic linkages between the Parties; lower costs; increase intra-regional trade and investment; increase economic efficiency; create a larger market with greater opportunities and larger economies of scale for the businesses of the Parties; and enhance the attractiveness of the Parties to capital and talent;

RECOGNISING the important role and contribution of the business sector in enhancing trade and investment between the Parties and the need to further promote and facilitate their cooperation and utilisation of greater business opportunities provided by the ASEAN-India RTIA;

RECOGNISING the different stages of economic development among ASEAN Member States and the need for flexibility, including the need to facilitate the increasing participation of Cambodia, Lao PDR, Myanmar and Viet Nam (the New ASEAN Member States) in the ASEAN-India economic co-operation and the expansion of their exports, inter alia, through the strengthening of their domestic capacity, efficiency and competitiveness;

REAFFIRMING the rights, obligations and undertakings of the respective parties under the World Trade Organisation (WTO), and other multilateral, regional and bilateral agreements and arrangements; and

RECOGNISING that regional trade arrangements can contribute towards accelerating regional and global liberalisation and as building blocks in the framework of the multilateral trading system,

HAVE AGREED AS FOLLOWS:

ARTICLE 1
Objectives

The objectives of this Agreement are to

a Strengthen and enhance economic, trade and investment co-operation between the Parties;
b Progressively liberalise and promote trade in goods and services as well as create a transparent, liberal and facilitative investment regime;
c Explore new areas and develop appropriate measures for closer economic co-operation between the Parties; and

c. Facilitate the more effective economic integration of the new ASEAN Member States and bridge the development gap among the Parties.

ARTICLE 2
Measures For Economic Cooperation

The Parties agree to enter into negotiations in order to establish an ASEAN-India Regional Trade and Investment Area (RTIA), which includes a Free Trade Area (FTA) in goods, services and investment, and to strengthen and enhance economic cooperation through the following:

a. Progressive elimination of tariffs and non-tariff barriers in substantially all trade in goods;
b. Progressive liberalisation of trade in services with substantial sectoral coverage;
c. Establishment of a liberal and competitive investment regime that facilitates and promotes investment within the ASEAN-India RTIA;
d. Provision of special and differential treatment to the New ASEAN Member States;
e. Provision of flexibility to the Parties in the ASEAN-India RTIA negotiations to address their sensitive areas in the goods, services and investment sectors with such flexibilities to be negotiated and mutually agreed based on the principle of reciprocity and mutual benefits;
f. Establishment of effective trade and investment facilitation measures, including, but not limited to, simplification of customs procedures and development of mutual recognition arrangements;
g. Expansion of economic cooperation in areas as may be mutually agreed between the Parties that will complement the deepening of trade and investment links between the Parties and formulation of action plans and programmes in order to implement the agreed sectors/areas of co-operation; and
h. Establishment of appropriate mechanisms for the purposes of effective implementation of this Agreement.

ARTICLE 3
Trade In Goods

1. With a view to expediting the expansion of trade in goods, the Parties agree to enter into negotiations in which duties and other restrictive regulations of commerce (except, where necessary, those permitted under Article XXIV (8)(b) of the WTO General Agreement on Tariffs and Trade (GATT)) shall be eliminated on substantially all trade in goods between the Parties.
2. For the purposes of this Article, the following definitions shall apply unless the context otherwise requires:

    a. "applied Most Favoured Nation (MFN) tariff rates" shall refer to the respective applied rates of the Parties as of 1 July 2004; and
    b. "non-tariff measures" shall include non-tariff barriers.

3. Upon signing of this Agreement, the Parties shall commence consultations on each other's trade regime, including, but not limited to the following:

    a. trade and tariff data;
    b. customs procedures, rules and regulations;
    c. non tariff measures including, but not limited to import licensing requirement and procedure, quantitative restrictions, technical barriers to trade, sanitary and phytosanitary;
    d. intellectual property rights rules and regulations; and
    e. trade policy.

4. The tariff reduction or elimination programme of the Parties shall require tariffs on listed products to be gradually reduced and, where applicable, eliminated in accordance with this Article.
5. The products which are subject to the tariff reduction or elimination programme under this Article shall include all products not covered by the Early Harvest Programme (EHP) under Article 7 of this

Agreement, and such products shall be categorised into two tracks as follows:

a. Normal Track. Products listed in the Normal Track by a Party on its own accord shall have their respective applied MFN tariff rates gradually reduced or eliminated in accordance with specified schedules and rates (to be mutually agreed by the Parties) over a period from:

   i. 1 January 2006 to 31 December 2011 for Brunei Darussalam, Indonesia, Malaysia, Singapore and Thailand, and India;
   ii. 1 January 2006 to 31 December 2016 for the Philippines and India; and
   iii. 1 January 2006 to 31 December 2011 for India and 1 January 2006 to 31 December 2016 for the New ASEAN Member States in respect of those tariffs which have been reduced but have not been eliminated, they shall be progressively eliminated within timeframes to be mutually agreed between the Parties.

b. Sensitive Track:

   i. The number of products listed in the Sensitive Track shall be subject to a maximum ceiling to be mutually agreed among the Parties
   ii. Products listed in the Sensitive Track by a Party on its own accord shall, where applicable, have their respective applied MFN tariff rates progressively reduced/eliminated within timeframes to be mutually agreed between the Parties

6 The commitments undertaken by the Parties under this Article and Article 7 of this Agreement shall fulfil the WTO requirements to eliminate tariffs on substantially all the trade between the Parties

7 The specified tariff rates/tariff preferences to be mutually agreed between the Parties pursuant to this Article shall set out only the limits of the applicable tariff rates/preferences or range for the specified year of implementation by the Parties.

8 The negotiations between the Parties to establish the ASEAN-India RTIA covering trade in goods shall also include, but not be limited to the following:

   a. modalities, including detailed rules governing the tariff reduction and/or elimination;
   b. Rules of Origin;
   c. treatment of out-of-quota rates;
   d. modification of a Party's commitments under the agreement on trade in goods based on WTO agreements;
   e. non-tariff measures/barriers, including, but not limited to, quantitative restrictions or prohibition on the importation of any product or on the export or sale for export of any product, as well as sanitary and phytosanitary measures and technical barriers to trade;
   f. safeguards based on the WTO agreements;
   g. disciplines on subsidies and countervailing measures and anti-dumping measures based on the existing WTO agreements; and
   h. facilitation and promotion of effective and adequate protection of trade-related aspects of intellectual property rights based on existing WTO, World Intellectual Property Organisation (WIPO) and other relevant agreements.

ARTICLE 4
Trade In Services

With a view to expediting the expansion of trade in services, the Parties agree to enter into negotiations to progressively liberalise trade in services on a preferential basis with substantial sectoral coverage. Such negotiations shall be directed to:

a. progressive elimination of substantially all discrimination between or among the Parties and/or prohibition of new or more discriminatory measures with respect to trade in services between the Parties, except for measures permitted under Article V(1)(b) of the WTO General Agreement on Trade in Services (GATS);
b. expansion in the depth and scope of liberalisation of trade in services beyond those undertaken by ASEAN Member States and India under the GATS; and
c. enhanced cooperation in services between the Parties in order to improve efficiency and competitiveness, as well as to diversify the supply and distribution of services of the respective service suppliers of the Parties.

ARTICLE 5
Investment

To promote investments and to create a liberal, facilitative, transparent and competitive investment regime, the Parties agree to:

a. enter into negotiations in order to progressively liberalise their investment regimes;
b. strengthen cooperation in investment, facilitate investment and improve transparency of investment rules and regulations; and
c. provide for the protection of investments.

ARTICLE 6
Areas of Economic Cooperation

1. Where appropriate, the Parties agree to strengthen their cooperation in the following areas, including, but not limited to:

   a. Trade Facilitation:

      i. Mutual Recognition Arrangements, conformity assessment, accreditation procedures, and standards and technical regulations;
      ii. non-tariff measures;
      iii. customs cooperation;
      iv. trade financing; and
      v. business visa and travel facilitation.

   b. Sectors of Cooperation:

      i. agriculture, fisheries and forestry;
      ii. services: media and entertainment, health, financial, tourism, construction, business process outsourcing, environmental;
      iii. mining and energy: oil and natural gas, power generation and supply;
      iv. science and technology: information and communications technology, electronic-commerce, biotechnology;
      v. transport and infrastructure: transport and communication;
      vi. manufacturing: automotive, drugs and pharmaceuticals, textiles, petrochemicals, garments, food processing, leather goods, light engineering goods, gems and jewellery processing;
      vii. human resource development: capacity building, education, technology transfer; and
      viii. others: handicrafts, small and medium enterprises, competition policy, Mekong Basin Development, intellectual property rights, government procurement.

c. Trade and Investment Promotion

i. fairs and exhibitions;
ii. ASEAN-India weblinks; and
iii. business sector dialogues

2. The Parties agree to implement capacity building programmes and technical assistance, particularly for the New ASEAN Member States, in order to adjust their economic structure and expand their trade and investment with India.

3. Parties may establish other bodies as may be necessary to coordinate and implement any economic cooperation activities undertaken pursuant to this Agreement.

ARTICLE 7
Early Harvest Programme

1. With a view to accelerating the implementation of this Agreement, the Parties agree to implement an EHP, which is an integral part of the ASEAN-India RTIA, for products covered under paragraph 3(a) below. The progressive tariff reduction under the EHP shall commence from 1 November 2004, and tariff elimination shall be completed by 31 October 2007 for ASEAN-6 and India, and 31 October 2010 for the New ASEAN Member States.

2. For the purposes of this Article, the following definitions shall apply unless the context otherwise requires:

a. "ASEAN 6" refers to Brunei Darussalam, Indonesia, Malaysia, the Philippines, Singapore and Thailand; and

b. "applied MFN tariff rates" shall refer to the respective applied rates of the Parties as of 1 July 2004.

3. The product coverage, tariff reduction and elimination, removal of non-tariff barriers, rules of origin, trade remedies and emergency measures applicable to the EHP shall be as follows:

a. Product Coverage

i. Common products on which the Parties agree to exchange tariff concessions are listed in Annex A.
ii. Products on which India accords concessions to the New ASEAN Member States are listed in Annex B

b. Modality for Tariff Reduction and Elimination

The modality for tariff reduction and elimination for the products covered by the EHP shall be finalised under Article 8(2) of this Agreement.

c. Removal of non-tariff measures

In order to fully realise the potential benefits of the EHP, the parties shall promote and facilitate trade in all products listed in the EHP. The parties shall also endeavour to refrain from using non-tariff measures adversely affecting trade in Early Harvest products.

d. Rules of Origin

Products covered by the EHP shall qualify for tariff preferences in accordance with

the Rules of Origin to be agreed under Article 8(2) of this Agreement.

e. Application of WTO provisions

The WTO provisions governing modification of commitments, safeguard actions, emergency measures and other trade remedies, including anti-dumping and subsidies and countervailing measures, shall, in the interim, be applicable to the products covered under the EHP and shall be superseded and replaced by the relevant disciplines negotiated and agreed to by the Parties under Article 3(8) of this Agreement once these disciplines are implemented.

4. The Parties shall also explore the feasibility of cooperation in the areas listed in Annex C.

ARTICLE 8
Timeframes

1. For trade in goods, negotiations on the agreement for tariff reduction/elimination and other matters as set out in Article 3 of this Agreement shall commence in January 2004 and be concluded by 30 June 2005 in order to establish the ASEAN-India FTA.
2. The negotiations on Rules of Origin for trade in goods under Articles 3 and 7 and modality for tariff reduction and elimination under Article 7 shall be concluded no later than 31 July 2004.
3. For trade in services and investments, the negotiations on the respective agreements shall commence in 2005 and be concluded by 2007. The identification, liberalisation, etc., of the sectors of services and investment shall be finalised for implementation subsequently in accordance with the timeframes to be mutually agreed: (a) taking into account the sensitive sectors of the Parties; and (b) with special and differential treatment and flexibility for the New ASEAN Member States.
4. For other areas of economic cooperation, the Parties shall continue to build upon existing or agreed programmes set out in Article 6 of this Agreement, develop new economic cooperation programmes and conclude agreements on the various areas of economic cooperation. The Parties shall do so expeditiously for early implementation in a manner and at a pace acceptable to all the Parties concerned. The agreements shall include timeframes for the implementation of the commitments therein.

ARTICLE 9
Most-Favoured Nation Treatment

India shall continue to accord Most-Favoured Nation (MFN) Treatment consistent with WTO rules and disciplines to all the non-WTO ASEAN Member States upon the date of signature of this Agreement.

ARTICLE 10
General Exceptions

Subject to the requirement that such measures are not applied in a manner which would constitute a means of arbitrary or unjustifiable discrimination between or among the Parties where the same conditions prevail, or a disguised restriction on trade within the ASEAN-India FTA, nothing in this Agreement shall prevent any Party from taking action and adopting measures for the protection of its national security or the protection of articles of artistic, historic and archaeological value, or such other measures which it deems necessary for the protection of public morals, or for the protection of human, animal or plant life, health and conservation of exhaustible natural resources.

ARTICLE 11
Dispute Settlement Mechanism

1. The Parties shall, within one (1) year after the date of entry into force of this Agreement, establish appropriate formal dispute settlement procedures and mechanism for the purposes of this Agreement.
2. Pending the establishment of the formal dispute settlement procedures and mechanism under

paragraph 1 above, any disputes concerning the interpretation, implementation or application of this Agreement shall be settled amicably by mutual consultations

ARTICLE 12
Institutional Arrangements for the Negotiations

1. There shall be established an ASEAN-India Trade Negotiating Committee (TNC) to carry out the programme of negotiations set out in this Agreement.
2. The ASEAN-India TNC may invite experts or establish any Working Group as may be necessary to assist in the negotiations of all sectors in the ASEAN-India RTIA.
3. The ASEAN-India TNC shall regularly report to the Minister of Commerce and Industry of India and the ASEAN Economic Ministers (AEM-India Consultations), through the meetings of the ASEAN Senior Economic Officials and India (SEOM-India Consultations), on the progress and outcome of its negotiations.
4. The Ministry of Commerce and Industry, Government of India, and the ASEAN Secretariat shall jointly provide the necessary secretariat support to the ASEAN-India Trade Negotiating Committee (TNC) whenever and wherever negotiations are held.

ARTICLE 13
Miscellaneous Provisions

1. This Agreement shall include the Annexes and the contents therein, and all future legal instruments agreed pursuant to this Agreement.
2. Except as otherwise provided in this Agreement, this Agreement or any action taken under it shall not affect or nullify the rights and obligations of a Party under existing agreements to which it is a party.
3. The Parties shall endeavour to refrain from increasing restrictions or limitations that would affect the application of this Agreement.
4. Any ASEAN Member State may defer its participation in the implementation of this Agreement provided that a notification is given to the other parties within twelve (12) months from the date of signing of this Agreement. Any extension of the negotiated concessions to such ASEAN Member State shall be voluntary on the part of the parties participating in such implementation. The ASEAN Member State concerned shall participate in the implementation of this Agreement at a later date on the same terms and conditions, including any further commitments that may have been undertaken by the other parties by the time of such participation.

ARTICLE 14
Amendments

The provisions of this Agreement may be modified through amendments mutually agreed upon in writing by the Parties.

ARTICLE 15
Depository

For the ASEAN Member States, this Agreement shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified copy thereof to each ASEAN Member State and India.

ARTICLE 16
Entry into Force

1. This Agreement shall enter into force on 1 July 2004.
2. The Parties undertake to complete their internal procedures for the entry into force of this Agreement prior to 1 July 2004.
3. Where a Party is unable to complete its internal procedures for the entry into force of this Agreement by 1 July 2004, the Agreement shall come into force for that Party upon the date of notification of the completion of its internal procedures. The Party concerned, however, shall be bound by the same

terms and conditions, including any further commitments that may have been undertaken by the other Parties under this Agreement by the time of such notification.

4. A Party shall upon the completion of its internal procedures for the entry into force of this Agreement notify all the other parties in writing.

IN WITNESS WHEREOF, we have signed this Framework Agreement on Comprehensive Economic Cooperation between the Association of Southeast Asian Nations and the Republic of India.

DONE at Bali, this 8th day of October, 2003 in duplicate copies in the English Language.

For Brunei Darussalam

HAJI HASSANAL BOLKIAH
Sultan of Brunei Darussalam

For the Republic of India

ATAL BIHARI VAJPAYEE
Prime Minister

For the Kingdom of Cambodia

SAMDECH HUN SEN
Prime Minister

For the Republic of Indonesia

MEGAWATI SOEKARNOPUTRI
President

For the Lao People's Democratic Republic

BOUNNHANG VORACHITH
Prime Minister

For Malaysia

DR MAHATHIR BIN MOHAMAD
Prime Minister

For the Union of Myanmar

GENERAL KHIN NYUNT
Prime Minister

For the Republic of the Philippines

GLORIA MACAPAGAL-ARROYO
President

For the Republic of Singapore

GOH CHOK TONG
Prime Minister

For the Kingdom of Thailand

DR. THAKSIN SHINAWATRA
Prime Minister

For the Socialist Republic of Viet Nam

PHAN VAN KHAI
Prime Minister

កិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្មទំនិញ
នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច
ចុលំចុណាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋឥណ្ឌា

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារ៉ូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបូរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋឥណ្ឌា។

ដោយរំលឹកឡើងវិញនូវ កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋឥណ្ឌា ដែលបានចុះហត្ថលេខាដោយប្រមុខរដ្ឋ/រដ្ឋាភិបាល នៃរដ្ឋជាសមាជិកអាស៊ាន និង ឥណ្ឌា នៅបាលី ប្រទេសឥណ្ឌូណេស៊ី កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៣ និង ពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋឥណ្ឌាដែលបានចុះហត្ថលេខា កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍។

ដោយរំលឹកឡើងវិញបន្ថែម លើមាត្រា ២ និង ៤ នៃពិធីសារវិសោធនកម្មលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋឥណ្ឌា ដែលបញ្ជាក់នូវការសន្យារបស់អាស៊ាន និង ឥណ្ឌា ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ដែលគ្របដណ្តប់ទៅលើពាណិជ្ជកម្មទំនិញនៅឆ្នាំ២០១៣ សម្រាប់ប្រទេសប្រ៊ុយណេដារ៉ូសាឡាំ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សឹង្ហបូរី ថៃឡង់ដ៍ និង ឥណ្ឌា និងនៅឆ្នាំ ២០១៨ សម្រាប់ហ្វីលីពីន និង ឥណ្ឌា ហើយនៅឆ្នាំ២០១៣ សម្រាប់ឥណ្ឌា និងនៅឆ្នាំ២០១៨ សម្រាប់កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម។

ដោយបញ្ជាក់ឡើងវិញ សារៈសំខាន់នៃប្រព្រឹត្តកម្មពិសេស និងផ្សេងពីគ្នា ដើម្បីធានាដល់ការចូលរួមបណ្តារដ្ឋសមាជិកអាស៊ានថ្មីក្នុងសកម្មភាពការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និង ឥណ្ឌា។

ដោយការអះអាងជាថ្មី នូវការសន្យារបស់គ្រប់ភាគីទាំងអស់ ក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ក្នុងពេលនោះដែរព្រមឱ្យមានភាពទន់ភ្លន់ដល់គ្រប់ភាគីទាំងអស់ ដើម្បីបង្ហាញនូវវិស័យវេទយិតភាពរបស់ខ្លួន ដូចបានចែងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

បានយល់ព្រមដូចតទៅ:

មាត្រា ១
និយមន័យ

គោលបំណងនៃកិច្ចព្រមព្រៀងនេះ និងវាក្យសព្ទ:

(ក) AIFTA មានន័យថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា។

(ខ) **អត្រាពន្ធអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត** (MFN) គឺសព្វបញ្ចូលទាំងអត្រាពន្ធកូតា ហើយនឹង:

(១) ក្នុងករណីរដ្ឋសមាជិកអាស៊ាន (ជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៧) និង សាធារណរដ្ឋឥណ្ឌា អត្រាពន្ធអនុវត្តរបស់ពួកគេ រៀងៗខ្លួន គឺអត្រាពន្ធនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ លើកលែងតែជលិតផល ដែលបានសម្គាល់ថាជាផលិផលដោយឡែកនៅក្នុងកម្មវិធីនៃការសន្យាពន្ធគយដូចបានចែងនៅក្នុងឧបសម្ព័ន្ធ ១។ និង

(២) ក្នុងករណីសមាជិកអាស៊ាន (ពុំមែនជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧) អត្រាពន្ធគយអនុវត្តទៅលើប្រទេសឥណ្ឌា គឺអត្រាពន្ធនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ លើកលែងតែជលិតផលដែលបានសម្គាល់ថាជាផលិផលដោយឡែកនៅក្នុងកម្មវិធី នៃការសន្យាពន្ធគយ ដូចបានចែងនៅក្នុងឧបសម្ព័ន្ធ ១។

(គ) **អាស៊ាន** មានន័យថា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលមានប្រទេសប៊្រុយណេដារ៉ូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលរួមគ្នាទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ ហៅថាបណ្តារដ្ឋសមាជិកអាស៊ាន និងប្រទេសនីមួយៗហៅថា រដ្ឋសមាជិកអាស៊ាន។

(ឃ) **កិច្ចព្រមព្រៀងក្របខ័ណ្ឌ** មានន័យថា កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌាដែលបានចុះហត្ថលេខានៅបាលី ប្រទេសឥណ្ឌូណេស៊ី កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៣ ដូចបានធ្វើវិសោធនកម្ម។

(ង) GATT 1994 មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដោយរាប់បញ្ចូលទាំងកំណត់សម្គាល់ និងបទប្បញ្ញត្តិបន្ថែមនានា។

(ច) **ទំនិញ** មានន័យថា វត្ថុជាតុដើម និង/ឬ ផលិតផល។

(ឆ) **ប្រភពដើមទំនិញ** មានន័យថា ទំនិញដែលមានគុណសម្បត្តិគ្រប់គ្រាន់ទៅតាមវិធាននៃប្រភពដើមទំនិញ នៅក្នុងមាត្រា ៧ នៃកិច្ចព្រមព្រៀងនេះ។

(ជ) **រដ្ឋសមាជិកអាស៊ានថ្មី** មានប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម។

(ឈ) **បណ្តាភាគី** មានន័យថា បណ្តារដ្ឋសមាជិកអាស៊ាន និង ឥណ្ឌា រួមទាំងអស់គ្នា។

(ញ) **ភាគីមួយ** មានន័យថា រដ្ឋសមាជិកអាស៊ាននីមួយៗ ឬ ឥណ្ឌា។

(ដ) **WTO** មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក។

(ប) កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក មានន័យថា កិច្ចព្រមព្រៀងម៉ារ៉ាហ្គេស ដែលបានបង្កើតអង្គការពាណិជ្ជកម្មពិភពលោក កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤។

មាត្រា ២
វិសាលភាព

កិច្ចព្រមព្រៀងនេះត្រូវអនុវត្តលើពាណិជ្ជកម្មទំនិញ និង បញ្ហាផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធដូចបានប្រមើលទុកនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

មាត្រា ៣
ប្រព្រឹត្តិកម្មជាតិស្តីពី ពន្ធអាករផ្ទៃក្នុង និងបទប្បញ្ញត្តិនានា

ភាគីនីមួយៗ ត្រូវយល់ព្រមផ្តល់ប្រព្រឹត្តិកម្មជាតិទៅលើទំនិញរបស់បណ្តាភាគីផ្សេងទៀត ឲ្យស្របទៅតាមមាត្រា ៣ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ ដែលនឹងអនុវត្តដូចអ្វីដែលបានកែប្រែទៅតាមកិច្ចព្រមព្រៀងនេះ។

មាត្រា ៤
ការកាត់បន្ថយ និង លុបបំបាត់ពន្ធគយ

១. លើកលែងអ្វីដែលបានចែងក្នុងកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវធ្វើសេរីភាវូបនីយកម្មជាបណ្តើរៗ ដែលអាចអនុវត្តបានអត្រាពន្ធប្រជាជាតិអនុគ្រោះបំផុតទៅលើទំនិញ ដែលមានប្រភពដើមមកពីបណ្តាភាគីផ្សេងទៀតស្របទៅតាមកម្មវិធីនៃការសន្យាកាត់បន្ថយអត្រាពន្ធគយរបស់ខ្លួន ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ ១។

២. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងរារាំងដល់ភាគីណាមួយចេញពីការបង្កើនល្បឿនការកាត់បន្ថយ និង/ឬ លុបបំបាត់ចោលនូវអត្រាពន្ធគយអនុគ្រោះបំផុតលើទំនិញមានប្រភពដើមមកពីបណ្តាភាគីផ្សេងទៀត ដូចមានចែងនៅក្នុងកម្មវិធីនៃការសន្យាកាត់បន្ថយអត្រាពន្ធគយរបស់ខ្លួនក្នុងឧបសម្ព័ន្ធ ១ នោះទេ។

៣. លើកលែងតែអ្វីដែលបានចែងនៅក្នុងកថាខ័ណ្ឌ ១ រាល់ការសន្យាទាំងអស់ដែលបានផ្តល់ដោយភាគីនីមួយៗ នៅក្រោមមាត្រានេះនឹងត្រូវបានអនុវត្តដល់គ្រប់បណ្តាភាគីផ្សេងទៀត។

មាត្រា ៥
តម្លាភាព

មាត្រា X នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ ត្រូវបានបញ្ចូលដូចអ្វីដែលបានកែប្រែទៅក្នុង និងបង្កើតជាផ្នែកមួយ នៃកិច្ចព្រមព្រៀងនេះ។

មាត្រា ៦
ផ្លែសេនាគ្រាប់គ្រែង និងធម្មជំការ

ភាគីនីមួយៗអះអាងជាថ្មីនូវការសន្យារបស់ខ្លួនស្ថិតនៅក្រោមមាត្រា VIII.1 នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ (GATT 1994)។

មាត្រា ៧
វិធានប្រតិពាដើម

វិធានប្រតិពាដើម និងនីតិវិធីបញ្ជាក់ប្រតិបត្តិការអាចអនុវត្តបានទៅលើទំនិញទាំងអស់នៅក្រោមកិច្ចព្រមព្រៀងនេះ មានចែងនៅក្នុងឧបសម្ព័ន្ធ ២ និងក្នុងបរិសិដ្ឋរបស់វា។

មាត្រា ៨
វិធានការមិនមែនពន្ធគយ

១. ភាគីនីមួយៗនឹង:

(ក) មិនបង្កើត ឬ រក្សាទុកវិធានការមិនមែនពន្ធគយណាមួយ ទៅលើការនាំចូលទំនិញមកពីបណ្តាភាគីផ្សេងទៀត ឬ លើការនាំទំនិញចេញ ឬ ការលក់សម្រាប់នាំចេញនៃទំនិញបានឆ្ពោះទៅកាន់ទឹកដីរបស់បណ្តាភាគីផ្សេងទៀត លើកលែងតែអ្វីស្របទៅតាមសិទ្ធិ និងកាតព្វកិច្ចរបស់អង្គការពាណិជ្ជកម្មពិភពលោក ឬ បទប្បញ្ញត្តិផ្សេងទៀតនៅក្នុងកិច្ចព្រមព្រៀងនេះ។ និង

(ខ) ធានាតម្លាភាព នៃវិធានការមិនមែនពន្ធគយរបស់ខ្លួន បានអនុញ្ញាតក្រោមកថាខ័ណ្ឌរង (ក) និងបំពេញទាំងស្រុងនូវកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ក្នុងទស្សនៈការរំខានដល់ពាណិជ្ជកម្មតិចតួចបំផុតអាចធ្វើទៅបាន និងពង្រីកពាណិជ្ជកម្មជាអតិបរមាដែលអាចធ្វើទៅបាន។

២. បណ្តាភាគីធ្វើការអះអាងជាថ្មីពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្ម ក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យ ក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក រាប់បញ្ចូលទាំងនីតិវិធីនៃការជូនដំណឹងលើការរៀបចំបទដ្ឋានពាក់ព័ន្ធដើម្បីកាត់បន្ថយផលអវិជ្ជមានលើពាណិជ្ជកម្ម ក៏ដូចជាការការពារជីវិត ឬ សុខភាពមនុស្ស សត្វ ឬ រុក្ខជាតិ។

៣. ភាគីនីមួយៗ ត្រូវបង្កើតកន្លែងទំនាក់ទំនងរបស់ខ្លួនក្នុងគោលបំណងនៃការឆ្លើយតបនានាទៅលើសំណើពាក់ព័ន្ធនានារបស់មាត្រានេះ។

មាត្រា ៩
ការកែប្រែនៃការធ្វើសម្បទាន

១. បណ្តាភាគីទាំងអស់នឹងមិនត្រូវបដិសេធ ឬ លំអៀងនៃសម្បទានណាមួយបានធ្វើឡើងដោយពួកខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះទេ លើកលែងតែក្នុងករណីមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។

២. ភាគីនីមួយៗ អាចធ្វើការកែប្រែឬដកចេញសម្បទាន ដែលបានផ្តល់នៅក្រោមកិច្ចព្រមព្រៀងនេះដោយការចរចា និងការព្រមព្រៀងជាមួយភាគីណាមួយផ្សេងទៀត ដែលខ្លួនបានធ្វើសម្បទាន។ ការចរចា និងការព្រមព្រៀងទាំងនោះ អាចបញ្ចូលបទប្បញ្ញត្តិសម្រាប់ការកែតម្រូវសំណងចំពោះទំនិញផ្សេងទៀតបណ្តាភាគីពាក់ព័ន្ធនឹងរក្សាកំរិតទូទៅនៃបដិការ ឬ សម្បទានផលចំណេញទៅវិញទៅមកមិនតិចជាងភាពអនុគ្រោះបំផុតលើពាណិជ្ជកម្ម ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះពីមុនការឯកភាព។

ជំពូក ១០
វិបាននៃការការពារ

១. ភាគីនីមួយៗ ដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកអាចរក្សាសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រា XIX នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីការការពារនៅក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (កិច្ចព្រមព្រៀងស្តីពីការការពារ) និងមាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្មនៅក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (កិច្ចព្រមព្រៀងស្តីពីកសិកម្ម)។ សកម្មភាពណាមួយបានអនុវត្តស្របទៅតាមមាត្រា XIX នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីការការពារ ឬ មាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្មនឹងមិនត្រូវគ្លាយជាប្រធានបទលើកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយជម្លោះនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះទេ (កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយជម្លោះអាស៊ាន-ឥណ្ឌា)។

២. ភាគីមួយនឹងមានសិទ្ធិផ្តួចផ្តើមដាក់វិធានការការពារលើទំនិញមួយ នៅក្រោមមាត្រានេះ (វិធានការការពារតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា) លើទំនិញក្នុងរយៈពេលអន្តរកាលសម្រាប់ទំនិញនោះ។ រយៈពេលអន្តរកាលសំរាប់ទំនិញត្រូវចាប់ផ្តើមពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កិច្ចព្រមព្រៀងនេះ និងត្រូវបញ្ចប់រយៈពេល៥ឆ្នាំ បន្ទាប់ពីថ្ងៃបញ្ចប់នៃការកាត់បន្ថយ/ការលុបបំបាត់ពន្ធគយសំរាប់ទំនិញនោះ។

៣. ភាគីមួយមានសេរីភាពពេញលេញ ក្នុងការប្រើវិធានការការពាររបស់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ប្រសិនបើផលនៃកាតព្វកិច្ចនានាបានកើតឡើងដោយភាគីនោះនៅក្រោមកិច្ចព្រមព្រៀងនេះទំនិញកំពុងបាននាំចូលពីភាគីនានាផ្សេងៗទៀត ដែលអត្រាពន្ធសម្បទានបានកំពុងធ្វើទៅលើទំនិញ នោះដូចជាបានបង្កើនបរិមាណទាំងស្រុង ឬ ទាក់ទងទៅនឹងផលិតផលក្នុងស្រុក និងនៅក្រោមលក្ខខណ្ឌនានាដូចគ្នានេះបានបង្កអោយ ឬ បានគំរាមយ៉ាងធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកនៃភាគីនាំចូលផលិតដូចគ្នានោះ ឬទំនិញដែលប្រកួតប្រជែងដោយផ្ទាល់ក្នុងទឹកដីរបស់ខ្លួន។

៤. ប្រសិនបើវិធានការការពារតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ត្រូវបានអនុវត្តដោយភាគីមួយភាគីអនុវត្តវិធានការនោះអាច :

(ក) ព្យួរទុកជាបណ្តោះអាសន្ននូវការកាត់បន្ថយអត្រាពន្ធគយ បន្ថែមទៀតក្រោមកិច្ចព្រមព្រៀងនេះ សម្រាប់ទំនិញនោះ។ ឬ

(ខ) បង្កើនអត្រាពន្ធគយទៅលើទំនិញពាក់ព័ន្ធទៅកំរិតមួយដែលមិនលើសពីកំរិតនៃ:

(១) អត្រាពន្ធអនុវត្តប្រជាជាតិគ្រោះបំផុត (MFN) លើទំនិញក្នុងផលប៉ះពាល់ នៅពេលសកម្មភាពនោះបានកំពុងអនុវត្ត ឬ

(២) អត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុត (MFN) លើទំនិញក្នុងផលប៉ះពាល់នៅថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

៥. វិធានការការពារតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា អាចត្រូវបានរក្សាទុកចាប់ពីរយៈពេលផ្តួចផ្តើមរហូតដល់បី (៣) ឆ្នាំ ហើយអាចពន្យារបានតែមិនអាចលើសពីមួយ (១) ឆ្នាំទេ បើសិនវិធានការនេះបានកំណត់ស្របតាមនីតិវិធី ដូចបានចែងនៅក្នុងកថាខ័ណ្ឌ ៦ ដែលវិធានការនេះចាំបាច់ត្រូវបន្តសម្រាប់រារាំង ឬ ដោះស្រាយការគ្រោះថ្នាក់ធ្ងន់ធ្ងរ និង ជួយសំរួលដល់ការកែលំអស្ថានភាព និងទាំងនេះជាភស្តុតាងបញ្ជាក់ថាឧស្សាហកម្មក្នុងស្រុកកំពុងត្រូវបានធ្វើការកែលំអ។ ថ្វីបើមានរយៈពេលនៃវិធានការការពារតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាលើទំនិញ ក៏ដោយវិធានការការពារនោះនឹងបញ្ចប់ក្នុងពេលចុងក្រោយ នៃរយៈពេលអន្តរកាលសម្រាប់ទំនិញនោះ។

៦. ក្នុងការអនុវត្តវិធានការការពារសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា បណ្តាភាគីត្រូវយល់ព្រម និងអនុវត្តដូចអ្វីដែលបានកែប្រែរាល់វិធាន នៃការស្នើសុំការអនុវត្តវិធានការការពារទាំងនោះរាប់បញ្ចូលទាំងបទប្បញ្ញត្តិវិធានការនានា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការការពារជាមួយការលើកលែងនៃវិធានការកំរិតបរិមាណ ដូចមានចែងនៅក្នុងមាត្រា ៥ និង ៧ និងក្នុងមាត្រា ៩ ១៣ និង ១៩ ផងដែរ នៃកិច្ចព្រមព្រៀងស្តីពីការការពារ។

៧. វិធានការការពារតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា នឹងមិនត្រូវបានអនុវត្តប្រឆាំងទល់នឹងទំនិញមានប្រភពដើមនៅក្នុងទឹកដីរបស់ភាគីមួយយ៉ាងយូរនោះទេ ដែលចំណែកនៃការនាំចូលរបស់ទំនិញពាក់ព័ន្ធនៅក្នុងភាគីនាំចូលមានមិនលើសពីបីភាគរយ (៣%) នៃបរិមាណនាំចូលសរុបរបស់ទំនិញនោះពីបណ្តាភាគីផ្សេងទៀត។

៨. ក្នុងការស្វែងរកសំណងនៅក្រោមមាត្រា ៨ នៃកិច្ចព្រមព្រៀងស្តីពីវិធានការការពារសម្រាប់វិធានការការពារក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា បណ្តាភាគីពាក់ព័ន្ធទាំងអស់នឹងស្វែងរកការិយាល័យនៃគណៈកម្មាធិការរួម ដែលបានបង្កើតនៅក្រោមមាត្រា ១៧ ដើម្បីកំណត់កំរិតសមមូលនៃសម្បទានដែលមានស្រាប់នៅក្រោមកិច្ចព្រមព្រៀងរវាងភាគីបានអនុវត្តវិធានការការពារ និងបណ្តាភាគីនាំចេញដែលត្រូវបានទទួលផលប៉ះពាល់ពីវិធានការនេះ មុនពេលការព្យួរណាមួយនៃសំណងសមមូល។ រាល់បណ្តឹងណាមួយបានកើតឡើងពីការិយាល័យនឹងត្រូវបំពេញក្នុងរយៈពេល ៩០ថ្ងៃ បន្ទាប់ពីថ្ងៃដែលវិធានការការពារសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា បានត្រូវអនុវត្ត។

៩. ប្រសិនបើ គ្មានការព្រមព្រៀងគ្នាលើសំណងក្នុងរយៈពេលដូចបានកំណត់ បានបញ្ជាក់នៅក្នុងកថាខ័ណ្ឌ ៨ បណ្តាភាគីជាប់ពាក់ព័ន្ធត្រូវមានសិទ្ធពន្យារការអនុវត្តនៃអត្រាពន្ធសម្បទាននៅក្រោមកិច្ចព្រមព្រៀងនេះដែលមានតំលៃស្មើគ្នាទៅនឹងវិធានការការពារ ក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាស្តីពីទំនិញប្រភពដើមរបស់ភាគីកំពុងបានអនុវត្តវិធានការការពារក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា។

១០. ការបញ្ចប់នៃវិធានការការពារ នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាលើទំនិញរបស់ភាគីមួយអនុលោមតាមតារាងការកាត់បន្ថយ និងការលុបបំបាត់អត្រាពន្ធរបស់ភាគីនោះ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ១ អត្រាពន្ធសម្រាប់ទំនិញនោះនឹងមានអត្រាពន្ធ នឹងមានប្រសិទ្ធិភាពមានវិធានការនេះដែលមិនត្រូវអនុវត្ត។

១១. ថ្វីបើមានបទប្បញ្ញត្តិនានានៃមាត្រានេះ គ្មានភាគីណាមួយអាចដាក់វិធានការការពារតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាលើទំនិញដែលសកម្មភាពបានកំពុងអនុវត្ត យោងទៅតាមមាត្រា XIX នៃ កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ និង កិច្ចព្រមព្រៀងស្តីពីការការពារ ឬ មាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម។ យោងតាមមាត្រា XIX នៃកិច្ចព្រមព្រៀងទូទៅស្តីពី ពន្ធគយនិង ពាណិជ្ជកម្ម ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីការការពារ ឬ មាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្មនៅពេលណាភាគីមួយមានបំណងចង់អនុវត្តសកម្មភាពលើទំនិញមួយ ដែលវិធានការការពារតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាបានកំពុងអនុវត្ត វាត្រូវបញ្ចប់វិធានការការពារតំបន់ពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា មុនការដាក់សកម្មភាពដែលនឹងត្រូវអនុវត្តយោងតាមមាត្រា XIX នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និង ពាណិជ្ជកម្ម ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីការការពារ ឬ មាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម។

១២. រាល់ឯកសារ និងទំនាក់ទំនងផ្លូវការទាំងអស់បានធ្វើការផ្លាស់ប្តូរក្នុងចំណោមភាគីទាំងអស់និងជាមួយគណៈកម្មាធិការរួមទាក់ទងទៅនឹង វិធានការការពារតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាត្រូវសរសេរជាលាយលក្ខណ៍អក្សរ និងត្រូវតែជាភាសាអង់គ្លេស។

មាត្រា ១១
វិធានការការពារជញ្ជីងទូទាត់

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីរារាំងភាគីមួយទៀតក្នុងការចាត់វិធានការណាមួយក្នុងគោលបំណងនៃជញ្ជីងទូទាត់ឡើយ។ ភាគីដែលចាត់វិធានការបែបនេះត្រូវធ្វើស្របតាមលក្ខខណ្ឌដែលបានបង្កើតនៅក្រោមមាត្រា XII នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ និងការយោគយល់គ្នាស្តីពីបទប្បញ្ញត្តិជញ្ជីងទូទាត់ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និង ពាណិជ្ជកម្ម ឆ្នាំ១៩៩៤ ក្នុងឧបសម្ព័ន្ធទី 1A នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។

មាត្រា ១២
ការលើកលែងទូទៅ

ភាគីនីមួយៗរក្សាទុកសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន នៅក្រោមមាត្រា XX នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ ដែលត្រូវបានបញ្ចូល (បើចាំបាច់)ទៅក្នុង និងបង្កើតបានជាផ្នែកមួយ នៃកិច្ចព្រមព្រៀងនេះ។

មាត្រា ១៣
ការលើកលែងផ្នែកសន្តិសុខ

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបានបកស្រាយ :

(ក) តម្រូវដល់ភាគីណាមួយបង្ហាញព័ត៌មាន ដែលពិចារណាទៅថ្មុយទៅនឹងផលប្រយោជន៍សន្តិសុខជាតិរបស់ខ្លួន។

(ខ) រារាំងភាគីណាមួយពីការធ្វើសកម្មភាពណាមួយ ដែលពិចារណាទៅឃើញថាចាំបាច់សម្រាប់ការការពារផលប្រយោជន៍សន្តិសុខជាតិរបស់ខ្លួន រួមទាំង :

(១) សកម្មភាពទាក់ទងទៅនឹងវត្ថុជាតិផ្ទុះ ឬវត្ថុដែលអាចផ្សំជាជាតិផ្ទុះបាន។

(២) សកម្មភាពដែលទាក់ទងទៅនឹងការធ្វើចរាចរអាវុធ អាវុធយុទ្ធភ័ណ្ឌ និងការអនុវត្តសម្រាប់សង្គ្រាម និងការធ្វើចរាចរលើទំនិញ និងវត្ថុធាតុផ្សេងៗទៀតដែលត្រូវយកទៅប្រើដោយផ្ទាល់ ឬ ដោយប្រយោលក្នុងគោលបំណង នៃការផ្គត់ផ្គង់ក្នុងការបង្កើតកងទ័ព។

(៣) សកម្មភាពដែលបានប្រើក្នុងការការពារហេដ្ឋារចនាសម្ព័ន្ធទំនាក់ទំនងសំខាន់ៗពីការព្យាយាមគិតទុកមុន ដើម្បីកំទេចចោល ឬ ធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។

(៤) សកម្មភាពដែលបានធ្វើក្នុងពេលមានសង្គ្រាម ឬ ក្នុងពេលបន្ទាន់ផ្សេងទៀតនៅក្នុងទំនាក់ទំនងអន្តរជាតិ ។ ឬ

(គ) រារាំងចំពោះភាគីណាមួយពីការប្រើសកម្មភាពណាមួយ ដែលស្របតាមកាតព្វកិច្ចរបស់ខ្លួននៅក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិសម្រាប់រក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

មាត្រា ១៤
នីតិវិធីគយ

១. ភាគីនីមួយៗ ត្រូវព្យាយាមអនុវត្តនីតិវិធីគយរបស់ខ្លួន តាមរបៀបការព្យាករណ៍សង្គតភាព និង តម្លាភាព ។

២. ដោយទទួលស្គាល់ពីសារៈសំខាន់នៃធ្វើឲ្យប្រសើរតម្លាភាព ក្នុងផ្នែកនីតិវិធីគយនៅក្នុងការស្នើសុំពីបុគ្គលចំណាប់អារម្មណ៍ម្នាក់នោះ ភាគីនីមួយៗនឹងខិតខំផ្តល់យ៉ាងប្រញាប់ និងត្រឹមត្រូវអាចធ្វើទៅបាននូវព័ត៌មានដែលទាក់ទងទៅនឹងនីតិវិធីគយរបស់ខ្លួន ដល់បុគ្គលចំណាប់អារម្មណ៍ជាប់ពាក់ព័ន្ធ។ ភាគីនីមួយៗត្រូវព្យាយាមផ្តល់នូវមិនមែនត្រឹមតែព័ត៌មានដែលបានស្នើសុំប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវផ្តល់ព័ត៌មានដែលជាប់ទាក់ទងផ្សេងទៀតដែលចាត់ទុកថាបុគ្គលចំណាប់អារម្មណ៍ទាំងនោះដែលគួរតែដឹង ។

៣. សម្រាប់ការបញ្ចេញទំនិញពីដែនគយឲ្យទាន់ពេលធ្វើពាណិជ្ជកម្ម ក្នុងចំណោមភាគីទាំងអស់ដោយទទួលស្គាល់នូវតួនាទីសំខាន់របស់អាជ្ញាធរគយ និងសារៈសំខាន់នៃនីតិវិធីគយក្នុងការធ្វើឲ្យប្រសើរដល់ការជួយសម្រួលពាណិជ្ជកម្ម ភាគីនីមួយៗត្រូវព្យាយាម :

(ក) ធ្វើអោយងាយស្រួលនូវនីតិវិធីគយរបស់ខ្លួន។ និង

(ខ) ធ្វើសុខដុមកម្មនីតិវិធីគយរបស់ខ្លួនតាមស្តង់ដារអន្តរជាតិ និងតាមអនុសាសន៍ក្នុងការប្រតិបត្តិដែលបានធ្វើនៅក្រោមការឧបត្ថម្ភ នៃអង្គការគយពិភពលោក។

មាត្រា ១៥
ការគ្រប់គ្រងតាមតំបន់ និងមូលដ្ឋាន

ក្នុងការបំពេញកាតព្វកិច្ច និងការសន្យាផ្តល់របស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀងនេះ និង យោងតាមបទប្បញ្ញត្តិនៃមាត្រា XXIV.១២ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ និងការយោគយល់គ្នាស្តីពីការបកស្រាយនៃមាត្រា XXIV នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និង ពាណិជ្ជកម្មឆ្នាំ១៩៩៤ ភាគីនីមួយៗចាត់វិធានការសមស្របតាមដែលខ្លួនអាចធ្វើទៅបាន ដើម្បីធានាការគ្រប់គ្រងដោយរដ្ឋ រដ្ឋបាលតំបន់ និងមូលដ្ឋាន និងអាជ្ញាធរនានានៅក្នុងទឹកដីរបស់ខ្លួន។

មាត្រា ១៦
ទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងផ្សេងទៀត

១. ភាគីនីមួយៗបញ្ជាក់ឡើងវិញនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួននៅចំពោះមុខភាគីមួយទៀត ក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងផ្សេងទៀតដែលបណ្តាភាគីទាំងនោះជាភាគីមួយរបស់កិច្ចព្រមព្រៀងនោះ។ ភាគីមួយដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកនឹងប្រព្រឹត្តទៅតាមបទប្បញ្ញត្តិនានា នៃកិច្ចព្រមព្រៀងខាងលើដោយអនុលោមតាមការសន្យាចូលរួមជាមួយអង្គការពាណិជ្ជកម្មពិភពលោក។

២. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបានបកស្រាយធ្វើអោយខូចសិទ្ធិ ឬ កាតព្វកិច្ចរបស់ភាគីមួយក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និង កិច្ចព្រមព្រៀងផ្សេងទៀតដែលបណ្តាភាគីទាំងនោះជាភាគីមួយរបស់កិច្ចព្រមព្រៀងទាំងនោះ។

៣. ក្នុងហេតុការណ៍នៃភាពមិនស្របគ្នាណាមួយរវាងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលភាគីពីរ ឬ ច្រើនជាភាគីនៃកិច្ចព្រមព្រៀងទាំងនោះ បណ្តាភាគីទាំងនោះនឹងធ្វើការពិគ្រោះយោបល់គ្នាជាបន្ទាន់ក្នុងទស្សនៈស្វែងរកនូវដំណោះស្រាយមួយពេញចិត្តទាំងសងខាង។

៤. កិច្ចព្រមព្រៀងនេះ នឹងមិនអនុវត្តទៅលើការព្រមព្រៀងណាមួយក្នុងចំណោមរដ្ឋសមាជិកអាស៊ាន ឬ ការព្រមព្រៀងណាមួយរវាងរដ្ឋសមាជិកអាស៊ានណាៗ និង ឥណ្ឌាឡើយលើកលែងតែបានឯកភាពដោយបណ្តាភាគីទាំងនោះទៅនឹងកិច្ចព្រមព្រៀងនោះ។

មាត្រា ១៧
គណៈកម្មាធិការរួម

១. គណៈកម្មាធិការរួមមួយត្រូវបានបង្កើតនៅក្រោមកិច្ចព្រមព្រៀងនេះ។

២. បណ្តាមុខងារនានា នៃគណៈកម្មាធិការរួមនឹងត្រូវមាន :

(ក) ពិនិត្យឡើងវិញនូវការប្រតិបត្តិ និងការអនុវត្តនៃកិច្ចព្រមព្រៀងនេះ។

(ខ) ដាក់ជូនរបាយការណ៍ទៅភាគីទាំងអស់ស្តីពីការអនុវត្ត និងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ។

(គ) ពិចារណា និងផ្តល់អនុសាសន៍ដល់បណ្តាភាគីទាំងអស់ក្នុងការកែប្រែណាមួយនៃកិច្ចព្រមព្រៀងនេះ។

(ឃ) ការណែនាំ និងសម្របសម្រួលការងាររបស់អនុគណៈកម្មាធិការនានាដែលបានបង្កើតឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ ។ និង

(ង) ការរ៉ាប់រងមុខងារផ្សេងទៀត ដូចជាមានការយល់ព្រមដោយបណ្តាភាគីទាំងអស់។

៣. គណៈកម្មាធិការរួម :

(ក) នឹងត្រូវមានតំណាងពីគ្រប់ភាគីទាំងអស់ ។ និង

(ខ) អាចបង្កើតអនុគណៈកម្មាធិការ និងផ្ទេរសិទ្ធិនៃការទទួលខុសត្រូវដល់អនុគណៈកម្មាធិការនោះ។

៤. គណៈកម្មាធិការរួមនឹងជួបប្រជុំនៅទីកន្លែង និងពេលណាមួយដូចបានព្រមព្រៀងគ្នាដោយបណ្តាភាគីទាំងនោះ។

មាត្រា ១៨
ការដោះស្រាយវិវាទ

លើកលែងតែអ្វីផ្សេងទៀតមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ វិវាទណាមួយពាក់ព័ន្ធទៅនឹងការបកស្រាយការប្រតិបត្តិ ឬ ការអនុវត្តកិច្ចព្រមព្រៀងនេះ នឹងត្រូវបានដោះស្រាយតាមរយៈ នីតិវិធី និងយន្តការដូចបានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីដំណើរការដោះស្រាយវិវាទ។

មាត្រា ១៩
ការពិនិត្យឡើងវិញ

គណៈកម្មាធិការរួមត្រូវជួបប្រជុំគ្នាម្តងក្នុងមួយឆ្នាំចាប់ពីកាលបរិច្ឆេទ នៃការចូលជាធរមានរបស់កិច្ចព្រមព្រៀងនេះ និងបន្ទាប់មកជួបប្រជុំគ្នាក្នុងរយៈពេលពីរឆ្នាំម្តង ឬ ទៅតាមពេលសមស្របក្នុងការពិនិត្យឡើងវិញ នៃកិច្ចព្រមព្រៀងនេះក្នុងគោលបំណងនៃការពិចារណាលើវិធានការបន្ថែមក្នុងការធ្វើឱ្យកានតែប្រសើរឡើងថែមទៀត នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ក៏ដូចជាអភិវឌ្ឍន៍វិនិយ និងចរចាលើកិច្ចព្រមព្រៀងនានាលើបញ្ហាពាក់ព័ន្ធនានា ដូចបានយល់ព្រមគ្នាកន្លងមក។

មាត្រា ២០
ឧបសម្ព័ន្ធនានា និង លិខិតូបករណ៍នានាអនាគត

១. ឧបសម្ព័ន្ធនានា និងឧបសំព័ន្ធនានាត្រូវបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

២. បណ្តាភាគីនានាអាចទទួលយកលិខិតូបករណ៍ក្នុងពេលអនាគត ដោយអនុលោមទៅតាមបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ រាជរដ្ឋាភិបាលទាំងសំណើរទៅឱ្យគេដោយគណៈកម្មាធិការរួម។ បន្ទាប់ពីការចូលជាធរមានរបស់គេរៀងៗខ្លួន លិខិតូបករណ៍ទាំងនោះត្រូវបង្កើតជាផ្នែកមួយ នៃកិច្ចព្រមព្រៀងនេះ។

មាត្រា ២១
វិសោធនកម្ម

១. កិច្ចព្រមព្រៀងនេះអាចត្រូវបានកែប្រែតាមរយៈការធ្វើវិសោធនកម្ម ដោយមានការយល់ព្រមគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរដោយភាគីទាំងអស់។ វិសោធនកម្មណាមួយនឹងចូលជាធរមាន បន្ទាប់ពីគ្រប់ភាគីទាំងអស់បានជូនដំណឹងដល់គ្រប់ភាគីផ្សេងទៀត ជាលាយលក្ខណ៍អក្សរនៃការបញ្ចប់នូវនីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាននូវវិសោធនកម្មនោះ។

២. ប៉ុន្តែបើមាននៅក្នុងកថាខ័ណ្ឌ ១ វិសោធនកម្មទាំងនោះពាក់ព័ន្ធទៅនឹង :

(ក) ឧបសម្ព័ន្ធ ១ បានចែងថាវិសោធនកម្មនានាបានធ្វើយោងទៅតាមវិសោធនកម្ម នៃប្រព័ន្ធសុខដុមកម្ម និងរាប់បញ្ចូលមិនមានផ្លាស់ប្តូរលើអត្រាពន្ធគយបានអនុវត្តលើទំនិញមានប្រភពដើមមកពីបណ្តាភាគីផ្សេងទៀតស្របជាមួយនឹងឧបសម្ព័ន្ធ ១ ។ និង

(ខ) ឧបសម្ព័ន្ធ ២ អាចធ្វើបានដោយមានការព្រមព្រៀងគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរដោយគ្រប់ភាគីទាំងអស់។

មាត្រា ២២
អន្តរតម្កល់ទុក

សម្រាប់រដ្ឋជាសមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះនឹងត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវចែកចាយភ្លាមនូវការថតចម្លងកិច្ចព្រមព្រៀងនោះ និងផ្ញើប្រាប់ចម្លងជូនដល់រដ្ឋជាសមាជិកអាស៊ាននីមួយៗ។

មាត្រា ២៣
ការចូលជាធរមាន

១. ភាគីនីមួយៗនឹងជូនដំណឹងដល់គ្រប់ភាគីទាំងអស់ ជាលាយលក្ខណ៍អក្សរបន្ទាប់ពីបានបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន[1] ក្នុងការធ្វើឲ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន។ កិច្ចព្រមព្រៀងនេះនឹងត្រូវចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ឬ នៅថ្ងៃដែលបានធ្វើការជូនដំណឹងដោយរដ្ឋាភិបាលឥណ្ឌា និងរដ្ឋជាសមាជិកអាស៊ានមួយយ៉ាងតិច។

២. នៅពេលដែលភាគីមួយមិនអាចបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ នោះកិច្ចព្រមព្រៀងនេះនឹងចូលជាធរមានសម្រាប់ភាគីនោះ ដោ

[1] ការសម្គាល់ថ្ងៃក្នុង) អាចរួមបញ្ចូលទាំងការមានទទួលការយល់ព្រមពីច្បាប់បាយ ឬពិធីផ្សេងទៀតតាមច្បាប់ក្នុងស្រុក។

ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០ ឬ នៅថ្ងៃដែលភាគីនោះបានជូនដំណឹងពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន។ ក្នុងករណី ដែលភាគីមួយមិនអាចបំពេញបាននូវនីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០ នោះកិច្ចព្រមព្រៀងនេះនឹងចូលជាធរមានសម្រាប់ភាគីនោះ បានជូនដំណឹងទៅភាគីទាំងអស់ពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន។

៣. ទាក់ទងដល់បណ្តាភាគីបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរយោងតាមកថាខ័ណ្ឌ ២ ភាគីទាំងនោះនឹងត្រូវបានចងតាមកាលកំណត់ និងលក្ខខណ្ឌនានាដូចគ្នានៃកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងការសន្យាបន្ថែមនានាដែលអាចត្រូវបានធ្វើឡើងដោយភាគីដទៃទៀត ក្រោមកិច្ចព្រមព្រៀងនេះក្នុងពេលវេលានៃការជូនដំណឹងនោះ ប្រសិនបើខ្លួនបានធ្វើការជូនដំណឹងដល់គ្រប់ភាគីទាំងអស់ជាលាយលក្ខណ៍អក្សរក្នុងការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនមុនកាលបរិច្ឆេទនៃការចូលជាធរមានរបស់កិច្ចព្រមព្រៀងនេះ។

មាត្រា ២៤
ការបញ្ចប់សុពលភាព

កិច្ចព្រមព្រៀងនេះ នឹងនៅជាធរមានរហូតដល់រដ្ឋជាសមាជិកអាស៊ានទាំងអស់ ឬ ក៍តណ្ឌារួមគ្នាបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីផ្សេងទៀត នូវបំណងក្នុងការបញ្ចប់សុពលភាព នៃកិច្ចព្រមព្រៀងនេះ ក្នុងករណីនេះកិច្ចព្រមព្រៀងនេះត្រូវបញ្ចប់សុពលភាពក្នុងរយៈពេល ១២ ខែ បន្ទាប់ពីថ្ងៃនៃការជូនដំណឹងពីការបញ្ចប់សុពលភាពមក។

ដើម្បីជាសាក្សីភាព ហត្ថលេខីដោយបានទទួលសិទ្ធិប្រទានត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួននីមួយៗ បានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងនេះ។

ធ្វើនៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ និងនៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ថ្ងៃទី.....ខែ.....ឆ្នាំ២០០៩ ជាច្បាប់ដើមចំនួនពីរជាភាសាអង់គ្លេស។

តំណាងរដ្ឋាភិបាលនៃ
ប្រទេសប្រ៊ុយណេដារ៉ូសាឡាំ

LIM JOCK SENG
Second Minister for Foreign Affairs and Trade

តំណាងរដ្ឋាភិបាលនៃ
ព្រះរាជាណាចក្រកម្ពុជា

CHAM PRASIDH
Senior Minister and Minister of Commerce

តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋឥណ្ឌា

ANAND SHARMA
Minister of Commerce and Industry

សាធារណរដ្ឋឥណ្ឌូណេស៊ី

MARI ELKA PANGESTU
Minister of Trade

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋ
ប្រជាធិបតេយ្យប្រជាមានិតឡាវ

NAM VIYAKETH
Minister of Industry and Commerce

តំណាងរដ្ឋាភិបាលនៃ
ប្រទេសម៉ាឡេស៊ី

MUSTAPA MOHAMED
Minister of International Trade and Industry
តំណាងរដ្ឋាភិបាលនៃ
សហភាពមីយ៉ាន់ម៉ា

U SOE THA
Minister for National Planning and Economic Development
តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋហ្វីលីពីន

PETER B. FAVILA
Secretary of Trade and Industry

តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋសិង្ហបូរី

LIM HNG KIANG

Minister for Trade and Industry

តំណាងរដ្ឋាភិបាលនៃ
ព្រះរាជាណាចក្រថៃឡង់ដ៍

PORNTIVA NAKASAI
Minister of Commerce

តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋសង្គមនិយមវៀតណាម

VU HUY HOANG
Minister of Industry and Trade

ឧបសម្ព័ន្ធ ១

តម្លៃទិដ្ឋីនៃការសន្យាពន្ធគយ
ស្រេចក្នុងឆ្នាល់

១. បន្ទាត់ពន្ធគយដែលជាកម្មវត្ថុលើការកាត់បន្ថយ និង/ឬ លុបបំបាត់ពន្ធគយ នៅក្រោមឧបសម្ព័ន្ធនេះត្រូវបានចាត់ចំណាត់ថ្នាក់ដូចតទៅ :

(ក) **តម្លៃទិដ្ឋីធម្មតា**

(១) អត្រាពន្ធប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) បន្ទាត់ពន្ធគយបានដាក់នៅក្នុងកម្មវិធីធម្មតានឹងត្រូវកាត់បន្ថយ និងលុបបំបាត់ជាបន្តបន្ទាប់ហោងទៅតាមតម្រូវនៃការកាត់បន្ថយ និងលុបបំបាត់ពន្ធគយដូចខាងក្រោម :

- កម្មវិធីធម្មតាទី ១ ៖

  សម្រាប់ប្រទេសប្រ៊ុយណេដារ៉ូសាឡាំ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ស៊ីង្ហបូរី និង ថៃឡង់ដ៍ និង ឥណ្ឌាចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៣ ។

  សម្រាប់ប្រទេស ហ្វីលីពីន និង ឥណ្ឌាចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ។

  សម្រាប់ប្រទេសឥណ្ឌា ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៣ និងសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ។

- កម្មវិធីធម្មតាទី ២ ៖

  សម្រាប់ប្រទេសប្រ៊ុយណេដារ៉ូសាឡាំ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ស៊ីង្ហបូរី និង ថៃឡង់ដ៍ និង ឥណ្ឌាចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ ។

  សម្រាប់ប្រទេសហ្វីលីពីន និង ឥណ្ឌា ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ។

  សម្រាប់ប្រទេសឥណ្ឌា ចាប់តំថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ និងសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀត-ណាមចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

(២) នៅពេលអត្រាពន្ធប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) សូន្យ (0%) ភាគរយអត្រានោះនឹងត្រូវរក្សានៅសូន្យ (0%) ភាគរយ។ នៅពេលដែលអត្រាពន្ធគយត្រូវបានកាត់បន្ថយមកដល់សូន្យ (0%) ភាគរយអត្រានោះទើបត្រូវរក្សានៅសូន្យ (0%) ភាគរយ។ គ្មានភាគីណាត្រូវបានអនុញ្ញាតតំឡើងអត្រាពន្ធគយលើបន្ទាត់ពន្ធគយណា

មួយឡើយ លើកលែងតែអត្រាពន្ធគយដូចដែលបានផ្តល់នៅក្នុងកិច្ចព្រមព្រៀងនេះ។

(ខ) **កម្មវិធីវេទយិតភាព**

(១) អត្រាពន្ធគយអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត(MFN)លើសពីប្រាំ (៥%)ភាគរយ សម្រាប់បន្ទាត់ពន្ធគយនៅក្នុងកម្មវិធីវេទយិតភាពនឹងត្រូវបានកាត់បន្ថយមកត្រឹមប្រាំ (៥%) ភាគរយយោងទៅតាមកម្មវិធីនៃការកាត់បន្ថយពន្ធគយដូចខាងក្រោម :

សម្រាប់ប្រទេសប្រ៊ុយណេដារ៉ូសាឡាំ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សឹង្ហបូរី និងថៃឡង់ដ៍ និង ឥណ្ឌាចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៦ ។

សម្រាប់ប្រទេស ហ្វីលីពីន និង ឥណ្ឌាចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ។

សម្រាប់ប្រទេសឥណ្ឌា ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ។

(២) អត្រាពន្ធគយអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) មានអត្រាប្រាំ (៥%) ភាគរយអាចត្រូវបានរក្សាទុកបានចំនួន ៥០ បន្ទាត់ពន្ធគយ។ សម្រាប់ចំនួនបន្ទាត់ពន្ធគយដែលនៅសល់ក្រៅពីនេះ ដែលមានអត្រាពន្ធគយអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) ត្រូវកាត់បន្ថយមកត្រឹម (៤.៥%) ភាគរយ នៅពេលចូលជាធរមាននៃកិច្ចព្រមព្រៀងនេះសម្រាប់ប្រទេសអាស៊ាន ៦[2] និងប្រាំ (៥) ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ សម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម។ អត្រាពន្ធគយអនុគ្រោះក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា សម្រាប់បន្ទាត់ពន្ធគយទាំងនោះត្រូវបានកាត់បន្ថយបន្ថែមមកត្រឹមបួន (៤%) ភាគរយដោយយោងតាមកាលបរិច្ឆេទចុងក្រោយ ដូចបានកំណត់ក្នុងកថាខ័ណ្ឌរង (១)។

(៣) អត្រាពន្ធគយអនុវត្តប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត (MFN) ចំនួនបួន (៤%) ភាគរយ នៃបន្ទាត់ពន្ធគយបានដាក់ក្នុងកម្មវិធីវេទយិតភាព ដូចដែលបានកំណត់ដោយភាគីនីមួយៗដូចដែលខ្លួនបានយល់ព្រម និងបានធ្វើការផ្លាស់ប្តូរជាមួយភាគីផ្សេងទៀត នឹងត្រូវលុបបំបាត់នៅ :

សម្រាប់ប្រទេសប្រ៊ុយណេដារ៉ូសាឡាំ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សឹង្ហបូរី[3] និងថៃឡង់ដ៍ និង ឥណ្ឌាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ។

សម្រាប់ប្រទេសហ្វីលីពីន និង ឥណ្ឌាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ។

[2] ការរៀបចំតំសេសសម្រាប់ ប្រទេសថៃឡង់អនុវត្ត

[3] ទម្រង់ការសេម្រាប់ដំណើរការវេយិតភាពដែលមិនអនុវត្តដល់ប្រទេសសឹង្ហបូរី

សម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៤ ។

(គ) **ផលិតផលពិសេស**

(១) ផលិតផលពិសេសរបស់ឥណ្ឌា មានប្រេងដូងឆៅ និងប្រេងដូងចំរាញ់រួច កាហ្វេ តែខ្មៅ និងម្រេច។

(២) អត្រាពន្ធគយអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) សម្រាប់ផលិតផលពិសេសនឹងត្រូវកាត់បន្ថយយោងទៅតាមកម្មវិធីកាត់បន្ថយពន្ធគយដូចខាងក្រោម :

បន្ទាត់ពន្ធគយ	អត្រាជាមូលដ្ឋាន	ពន្ធគយអនុគ្រោះតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា										
		មិនហួស ត្រឹមថ្ងៃទី ១ ខែ មករា										៣១.១២.២០១៩
		២០១០	២០១១	២០១២	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨	២០១៩	
ប្រេងដូងឆៅ	៨០	៧៦	៧២	៦៨	៦៤	៦០	៥៦	៥២	៤៨	៤៤	៤០	៣៧.៥
ប្រេងដូងផ្ទិន	៩០	៨៦	៨២	៧៨	៧៤	៧០	៦៦	៦២	៥៨	៥៤	៥០	៤៥
កាហ្វេ	១០០	៩៥	៩០	៨៥	៨០	៧៥	៧០	៦៥	៦០	៥៥	៥០	៤៥
តែខ្មៅ	១០០	៩៥	៩០	៨៥	៨០	៧៥	៧០	៦៥	៦០	៥៥	៥០	៤៥
ម្រេច	៧០	៦៨	៦៦	៦៤	៦២	៦០	៥៨	៥៦	៥៤	៥២	៥១	៥០

(៣) ការផ្តល់ណាមួយដែលប្រសើរជាងនេះ បានធ្វើឡើងដោយភាគីឥណ្ឌា សម្រាប់ភាគីផ្សេងទៀត លើការប្រកួតប្រជែងពីផលិតផលប្រេង/សារធាតុប្រេងក៏ត្រូវតែផ្តល់សម្រាប់ផលិតផលប្រេងដូងផងដែរ។

(៤) បើសិនអត្រាពន្ធគយអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) សម្រាប់ប្រេងដូងឆៅ និងប្រេងដូងចំរាញ់រួចទាបជាងអត្រាពន្ធអនុគ្រោះក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា អត្រាពន្ធដែលទាបជាងនោះនឹងត្រូវយកមកអនុវត្ត។

(ឃ) **បញ្ជីខ្លួនយឺតភាពខ្ពស់**[4]

[4] ទម្រង់ការសម្រាប់បញ្ជីវិយិតភាពខ្ពស់មិនអនុវត្តចំពោះ ប្រុយណេ, ឡាវ, មីយ៉ាន់ម៉ា និងសិង្ហបូរីឡើយ

បន្ទុះពន្ធគយ ដែលបានដាក់ទៅក្នុងបញ្ជីវេទយិតភាពខ្ពស់ដោយគ្រប់ភាគីប្រើប្រាស់ចែកជាបី (៣) ចំណាត់ថ្នាក់ ៖

(១) ចំណាត់ថ្នាក់ទី ១ ៖ ការកាត់បន្ថយអត្រាពន្ធគយអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) ទៅហាសឹប (៥០%) ភាគរយ។

(២) ចំណាត់ថ្នាក់ទី ២ ៖ ការកាត់បន្ថយអត្រាពន្ធគយអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) ដោយហាសឹប (៥០%) ភាគរយ។

(៣) ចំណាត់ថ្នាក់ទី ៣ ៖ ការកាត់បន្ថយអត្រាពន្ធគយអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) ដោយម្ភៃប្រាំ (២៥%) ភាគរយ។

និងការកាត់បន្ថយអត្រាពន្ធនេះនឹងត្រូវធ្វើឱ្យបានសម្រេចនៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ សម្រាប់ប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងថៃឡង់ដ៍ និងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ សម្រាប់ប្រទេសហ្វីលីពីន និងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ សម្រាប់ប្រទេសកម្ពុជា និងវៀតណាម។

(ខ) **បញ្ជីលើកលែង**

បញ្ជីលើកលែង នឹងត្រូវពិនិត្យឡើងវិញនូវអត្រាពន្ធប្រចាំឆ្នាំជាមួយនឹងទស្សនៈធ្វើឲ្យកាន់តែប្រសើរនូវដំណើរការចូលទៅទីផ្សារ។

២. គ្មានពន្ធគយអនុវត្តណាមួយរបស់បណ្តាភាគីទាំងអស់ នឹងលើសពីអត្រាក្នុងកម្មវិធីនៅក្នុងកិច្ចព្រមព្រៀងនេះឡើយ។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើអត្រាពន្ធគយអនុវត្តប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត (MFN) ទាបជាងអត្រាពន្ធក្នុងកម្មវិធីអត្រាពន្ធគយដែលទាប់ជាងនោះនឹងត្រូវអនុវត្តសម្រាប់គ្រប់ភាគីទាំងអស់។

៣. សម្រាប់បន្ទាត់ពន្ធគយដែលមានអត្រាពន្ធគយដោយឡែកការកាត់បន្ថយ និង/ឬ ការលុបបំបាត់ពន្ធគយត្រូវស្របទៅតាមគំរូ និងតារាងពេលវេលានៃចំណាត់ថ្នាក់ដែលបន្ទាត់ពន្ធគយទាំងនោះត្រូវបានដាក់បញ្ចូល។ សមាមាត្រនៃការកាត់បន្ថយអត្រាពន្ធគយសម្រាប់បន្ទាប់ពន្ធគយទាំងនេះ គឺស្មើនឹងមធ្យមភាពនៃការកាត់បន្ថយអត្រាពន្ធគយសម្រាប់បន្ទាប់ពន្ធគយជាភាគរយ នៃអត្រាពន្ធគយដែលជាកម្មវត្ថុនៃការកាត់បន្ថយពន្ធគយក្នុងឆ្នាំដូចគ្នា។

៤. ថ្វីបើមានកម្មវិធីនៅក្នុងឧបសម្ព័ន្ធនេះ គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះនឹងរារាំងភាគីណាមួយពីការធ្វើឯកតោភាគីក្នុងការពន្លឿនការកាត់បន្ថយអត្រាពន្ធគយ ឬ ធ្វើឯកតោភាគីក្នុងការផ្តល់ នៃផលិតផល ឬ បន្ទាត់ពន្ធគយក្នុងបញ្ជីវេទយិតភាពខ្ពស់ ឬ បញ្ជីផលិតផលពិសេសទៅក្នុងបញ្ជីវេទយិតភាព ឬ កម្មវិធីធម្មតាឡើយ ឬ ក៏បន្ទាត់ពន្ធគយនៅក្នុងបញ្ជីវេទយិតភាពទៅក្នុងកម្មវិធីធម្មតា ។

៥. បណ្តាភាគី នឹងរីករាយក្នុងការទទួលអត្រាពន្ធសម្បទាន បានធ្វើឡើងដោយភាគីផ្សេងៗទៀតសម្រាប់ បន្ទាត់ពន្ធគយដោយឡែក និងបានអនុវត្តស្របតាមកម្មវិធីនៃការកាត់បន្ថយ/ការលុបបំបាត់ពន្ធគយក្នុងឧបសម្ព័ន្ធនេះជាមួយការទទួលយក និងបណ្តាលក្ខខណ្ឌដែលមានចែងនៅក្នុងឧបសម្ព័ន្ធនេះដូចភាគីមួយបានប្រកាន់យកនូវការសន្យារបស់ខ្លួន សម្រាប់ការកាត់បន្ថយ/ការលុបបំបាត់ពន្ធគយសម្រាប់បន្ទាត់ពន្ធគយនោះ។

៦ អត្រាពន្ធគយដែលបានបញ្ជាក់នៅក្នុងកម្មវិធីក្នុងឧបសម្ព័ន្ធនេះ ជាទំនាបសម្រាប់តែគ្រឹតនៃអត្រាពន្ធគយអនុវត្តអនុគ្រោះតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាត្រូវអនុវត្តដោយភាគីនីមួយៗ សម្រាប់បន្ទាត់ពន្ធគយដែលពាក់ព័ន្ធក្នុងឆ្នាំដោយឡែកនៃការអនុវត្ត និងមិនរារាំងដល់ភាគីណាមួយពីការធ្វើឯកតោភាគីក្នុងការពន្លឿនការកាត់បន្ថយ ឬ ការលុបបំបាត់ពន្ធគយរបស់ខ្លួនក្នុងពេលណាមួយឡើយ។

៧. សម្រាប់ភាគីមួយដែលកិច្ចព្រមព្រៀងនេះ ចូលជាធរមាននៅក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ ២០១០ ការចាប់ផ្តើមការកាត់បន្ថយ ឬ ការលុបបំបាត់ពន្ធគយនឹងត្រូវបានអនុវត្តក្នុងតំរិតដែលបានកំណត់នៅក្នុងកម្មវិធីនៃការសន្យាពន្ធគយរបស់ភាគីនោះសម្រាប់ឆ្នាំ ដែលកិច្ចព្រមព្រៀងចូលជាធរមានសម្រាប់ភាគីនោះ។

<u>កម្មវិធីនៃការសន្យាចងភ្ជាប់</u>

<u>បញ្ជី ក</u>

ប្រ៊ុយណេដារ៉ូសាឡាំ

កម្ពុជា

ឥណ្ឌា

ឥណ្ឌូណេស៊ី

ឡាវ

ម៉ាឡេស៊ី

មីយ៉ាន់ម៉ា

សឹង្ហបូរី

ថៃឡង់ដ៍

វៀតណាម

<u>បញ្ជី ខ</u>

ឥណ្ឌា

ហ្វីលីពីន

ឧបសម្ព័ន្ធ ២

វិធានដើមកំណើតធំនិញ
សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា

ក្នុងការកំណត់ដើមកំណើត នៃផលិតផលដែលអាចទទួលបានអត្រាពន្ធប្រព្រឹត្តិកម្មអនុគ្រោះនៅក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា យោងតាមមាត្រា ៤ នៃកិច្ចព្រមព្រៀងនេះ វិធានទាំងអស់ដូចតទៅនេះនឹងត្រូវបានអនុវត្ត :

វិធានទី ១
និយមន័យ

គោលបំណងនៃឧបសម្ព័ន្ធនេះ និងវាទសព្ទ:

(ក) CIF មានន័យថា តម្លៃនៃទំនិញបាននាំចូល និងបូកបញ្ចូលទាំងថ្លៃដឹកជញ្ជូន និងថ្លៃធានារ៉ាប់រងរហូតដល់កំពង់ផែ ឬ ទីតន្លែងនៃការនាំចូលនៅក្នុងប្រទេសនាំចូល។

(ខ) FOB មានន័យថា តម្លៃដូចបានកំណត់នៅក្នុងកថាខ័ណ្ឌ ១ នៃបរិសិដ្ឋ ក មិនគិតថ្លៃដឹកជញ្ជូនានា។

(គ) **សម្ភារៈ** មានន័យថា វត្ថុធាតុដើម គ្រឿងផ្សំ គ្រឿងបន្លាស់ សមាសភាគ ការតម្លើងរាយរង និង/ឬ ទំនិញ ដែលត្រូវបានធ្វើទៅជាទំនិញមួយផ្សេងទៀត ឬ ជាប្រធានបទដំណើរការក្នុងការផលិតកម្មនៃទំនិញមួយផ្សេងទៀត។

(ឃ) **ផលិតផលប្រភពដើម** មានន័យថា ផលិតផលដែលបំពេញបាននូវលក្ខខណ្ឌប្រភពដើម យោងទៅតាមបទប្បញ្ញត្តិនៃវិធានទី ២។

(ង) **ផលិតកម្ម** មានន័យថា វិធីសាស្ត្រនៃការទទួលបានទំនិញ រួមទាំង ការដាំដុះ ពីរ៉ែ ការច្រូតកាត់ ការធំធាត់ ការបន្តពូជ ការទាញយក ការប្រមូលផល ការប្រមូលផ្តុំ ការចាប់ ការនេសាទ ការដាក់អន្ទាក់ ការប្រមាញ់ ការផលិត កម្មន្តសាលកម្ម ការកែច្នៃ ឬ ការផ្សំផ្គុំទំនិញ។

(ច) **វិធានផលិតជាក់លាក់** ជាវិធានដែលបញ្ជាក់ថា វត្ថុធាតុទាំងឡាយបានទទួលរងនូវការបំលែងនៅក្នុងចំណាត់ថ្នាក់ពន្ធគយ ឬ ដំណើរការផលិតកម្មជាក់លាក់ ឬ ប្រតិបត្តិការកែច្នៃ ឬ បំពេញតាមលក្ខណៈវិនិច្ឆ័យតម្លៃទំនិញ ឬ ការបង្រួមគ្នានៃលក្ខណៈវិនិច្ឆ័យណាមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងឡាយនេះ។

(ឆ) **ផលិតផល** មានន័យថា ផលិតផលដែលទទួលបានទាំងស្រុង/ផលិតបានទាំងស្រុង ឬ កំពុងធ្វើកម្មន្តសាល បើទោះបីវាត្រូវបានបំរុងទុកសម្រាប់ប្រើប្រាស់នៅពេលក្រោយក្នុងប្រតិបត្តិការកម្មន្តសាលមួយទៀតក្តី។

(ជ) **វត្ថុធាតុដូចគ្នាសុទ្ធសាធ និងអាចដោះដូរគ្នាបាន** មានន័យថា វត្ថុធាតុដែលកំពុងដំណើរការកែច្នៃប្រភេទដូចគ្នា មានចរិតលក្ខណៈបច្ចេកទេស និងលក្ខន្តិកៈប្រហាក់ប្រហែល និងវត្ថុធាតុមួយត្រូវបានប្រតិបត្តិការទៅជាផលិតផលសម្រេច ហើយមិនអាចកែញែកឱ្យដាច់ស្រឡះពីគ្នា ដើម្បីកំណត់ដូរប្រភពដើម ។

វិធានទី ២

លក្ខណៈវិនិច្ឆ័យប្រភពដើម

គោលបំណងនៃឧបសម្ព័ន្ធនេះ ផលិតផលបានទាំងស្រុងដោយភាគីមួយដែលបានបញ្ជូនដោយត្រង់ដូចន័យមាននៅក្នុងវិធានទី ៨ នឹងត្រូវបានចាត់ទុកជាទំនិញមានប្រភពដើម និងអាចទទួលបានអត្រាកាត់ប្រព្រឹត្តកម្មអនុគ្រោះ បើសិនទំនិញទាំងនោះសម្របទៅតាមលក្ខខណ្ឌតម្រូវណាមួយដូចខាងក្រោម :

(ក) ផលិតផលដែលទទួលបានមកទាំងស្រុង ឬ ផលិតកាន់ទាំងស្រុងនៅក្នុងភាគីនាំចេញដូចបានកំណត់ និងឲ្យអត្ថន័យនៅក្នុងវិធានទី ៣។ ឬ

(ខ) ផលិតផលដែលមិនទទួលបានមកទាំងស្រុង ឬ មិនផលិតបានទាំងស្រុងនៅក្នុងភាគីនាំចេញដែលបានកំណត់ថា ផលិតផលដែលពោលខាងលើអាចទទួលបានភាពអនុគ្រោះពន្ធនៅក្រោមវិធានទី ៥ ឬ ទី ៥ ឬ ទី ៦។

វិធានទី ៣

ផលិតផលទទួលបាន ឬ ផលិតបានទាំងស្រុង

នៅក្នុងអត្ថន័យនៃវិធានទី ២ (ក) ផលិតផលដូចខាងក្រោមត្រូវបានចាត់ទុកជាផលិតផលដែលទទួលបានមកទាំងស្រុង ឬ ផលិតកាន់ទាំងស្រុងនៅក្នុងភាគីមួយ :

(ក) រុក្ខជាតិ[5] និងផលិតផលរបស់រុក្ខជាតិបានធ្វើការដាំដុះ និងបេះ និងប្រមូលនៅក្នុងទឹកដីរបស់ភាគី។

(ខ) សត្វរស់[6] កើត និងចំណាត់នៅក្នុងទឹកដីរបស់ភាគីនោះ។

(គ) ផលិតផល[7] បានមកពីសត្វរស់ ដូចមាននៅក្នុងកថាខ័ណ្ឌ (ខ)។

(ឃ) ផលិតផលបានមកពីការប្រមាញ់ ការទាក់ ការនេសាទ ការចិញ្ចឹម ការប្រមូល ឬ ចាប់ប្រមូលបាននៅក្នុងទឹកដីរបស់ភាគីនោះ។

---

[5] រុក្ខជាតិនេះ សំដៅចំពោះគ្រប់រុក្ខជាតិរស់ រាប់បញ្ចូលទាំងផលិតផលព្រៃឈើ ផ្លែឈើ ផ្កា បន្លែ ដើមឈើ រុក្ខជាតិសាហាយ, ផ្សិតចំបុះ និង រុក្ខជាតិរស់ ។

[6] សត្វយោងទៅតាមកថាខ័ណ្ឌ (ខ) និង (គ) គឺសត្វរស់ទាំងអស់ រួមទាំងកង្វែនសត្វ សត្វល្អិត ត្រី សត្តរន្តជាតិ សប្បិជាតិ ឧរង្គសត្វ និងសត្វកង្គរស់ទាំងឡាយ ។

[7] ផលិតផលទាំងឡាយសំដៅចំពោះផលិតផលដែលបានទទួលពីសត្វជាមូលដ្ឋាន រួមទាំងការកែច្នៃ ដែលរាប់បញ្ចូលទាំង ទឹកដោះគោ ស៊ុត ទឹកឃ្មុំ ផលិតផលជាតិ រោម សក់ ទឹកកាម និងលាមកសត្វ

(ង) រ៉ែ និងសារធាតុដែលកើតមកពីធម្មជាតិដទៃទៀតមិនបានរាប់បញ្ចូលក្នុងកថាខ័ណ្ឌ (ក)ដល់ (ឃ) ដែលយកចេញពីក្នុងដី ទឹក បាតសមុទ្រ ឬ ក្រោមបាតសមុទ្ររបស់ភាគីនោះ។

(ច) ផលិតផលដែលយកចេញពីទឹក បាតសមុទ្រ ឬ ក្រោមបាតសមុទ្រ ខាងក្រៅដែនទឹករបស់ភាគី បានបញ្ជាក់ថាភាគីនោះមានសិទ្ធិ ដើម្បីធ្វើអាជីវកម្មក្នុងដែនទឹកបាតសមុទ្រ និងក្រោមបាតសមុទ្រ ដោយអនុលោមតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ឆ្នាំ ១៩៨២ ។

(ឆ) ផលិតផលនេសាទសមុទ្រ និងផលិតផលនេសាទតាមសមុទ្រផ្សេងទៀត ដែលនេសាទមកពីសមុទ្រជ្រៅ ដោយកប៉ាល់បានធ្វើការចុះបញ្ជីជាមួយភាគីមួយ និងបានទទួលសិទ្ធិបង្ហោះទង់ជាតិរបស់ភាគីនោះ ។

(ជ) ផលិតផលកែច្នៃ និង/ឬ បានផលិតនៅក្នុងរោងចក្រលើកប៉ាល់ដែលបានចុះបញ្ជីរួចហើយជាមួយភាគីមួយ និងបានទទួលសិទ្ធិបង្ហោះទង់ជាតិនៃភាគីនោះទទួលសិទ្ធិផ្តាច់មុខពីផលិតផលដែលបានចែងក្នុងកថាខ័ណ្ឌ (ឆ)។

(ឈ) របស់របរដែលបានប្រមូលផ្តុំនៅក្នុងភាគីមួយ ដែលមិនអាចចាត់ចែងតាមគោលបំណងប្រភពដើមរបស់ខ្លួនឱ្យបានយូរអង្វែង ទាំងមិនអាចមានលទ្ធភាពក្នុងការស្តុកទុកឡើងវិញ ឬ ជួសជុលបាន ហើយផ្គត់ផ្គង់សម្រាប់តែការចែកចាយ ឬ ការទទួលបាននូវវត្ថុធាតុដើមវិញប៉ុណ្ណោះ ឬ សម្រាប់ការកែច្នៃឡើងវិញតាមគោលបំណង[8] ប៉ុណ្ណោះ។

(ញ) ផលិតផលដែលទទួលបានទាំងស្រុង ឬ ផលិតទាំងស្រុងដោយភាគីមួយតែឯងពីផលិតផលដែលបានរៀបរាប់នៅក្នុងកថាខ័ណ្ឌ (ក) ដល់ (ឈ)។

វិធានទី ៤

ផលិតផលមិនទទួលបាន ឬមិនផលិតបានទាំងស្រុង

(ក) សម្រាប់គោលបំណងនៃវិធានទី ២ (ខ) ផលិតផលមួយនឹងត្រូវបានចាត់ទុកថាមានប្រភពដើមប្រសិនបើ :

(១) សមាសធាតុផ្សំតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា គឺមិនតិចជាង ៣៥% ភាគរយនៃតម្លៃ FOB ។ និង

[8] នេះនឹងគ្របដណ្តប់លើកំទេចកំទី និង កាកសំណល់ រួមមានកំទេចកំទី និង កាកសំណល់ដែលជាលទ្ធផលមកពីប្រតិបត្តិការ ផលិតកម្ម និង កែច្នៃ ឬ ការប្រើប្រាស់នៅក្នុងប្រទេស ដែលផលិតដូចគ្នា, គ្រឿងម៉ាស៊ីនកំទេចកំទី, កញ្ចប់ដែលរបោះ បង់ចោល និងផលិតផលទាំងអស់ដែលមិនអាចចាត់ចែងធ្វើតាមគោលបំណងយៈពេលយូរ សម្រាប់អ្វីដែលវា បានត្រូវផលិត និងត្រូវបានចំពេញសំរាប់ការបោះបង់ចោល

(២) វត្ថុធាតុដើមដែលមិនមានប្រភពដើមនៅក្នុងភាគីនោះ បានទទួលរងនូវការផ្លាស់ប្តូរក្នុងកំរិតអនុនៃលេខកូដក្នុងតារាងពន្ធគយ(CTSH)យ៉ាងតិចនៃប្រព័ន្ធសុខដុមកម្ម។

ជាចែងថា ដំណើរការចុងក្រោយនៃផលិតកម្មត្រូវបានធ្វើឡើងនៅក្នុងទឹកដីរបស់ភាគីនាំចេញ។

(ខ) សម្រាប់គោលបំណងនៃវិធាននេះរូបមន្ត ៣៥% ភាគរយសមាសធាតុផ្សំក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ត្រូវបានគណនាដូចខាងក្រោម[១]៖

(១) **<u>វិធីសាស្ត្រផ្ទាល់</u>** (Direct Methods)

$$\frac{\text{ថ្លៃដើមវត្ថុធាតុដើម + ថ្លៃដើម + ថ្លៃដើម + ថ្លៃដើម + ប្រាក់ចំណេញ}}{\text{តម្លៃ FOB}} \times ១០០\% \geq ៣៥\%$$

(២) **<u>វិធីសាស្ត្រប្រយោល</u>** (Indirect Methods)

$$\frac{\text{តម្លៃនៃការនាំចូលវត្ថុធាតុ ឬ គ្រឿងបន្លាស់មិន Non-AIFTA + តម្លៃវត្ថុធាតុ, គ្រឿងបន្លាស់ ឬការផលិត មិនបានកំណត់ប្រភពដើម}}{\text{តម្លៃ FOB}} \times ១០០\% \leq ៦៥\%$$

(គ) តម្លៃនៃវត្ថុធាតុដែលមិនមែនមានប្រភពដើមនឹងមាន :

(១) តម្លៃ CIF នៅពេលនៃការនាំចូលនៃវត្ថុធាតុ គ្រឿងបន្លាស់ ឬ ផលិតផល។

(២) ថ្លៃប្រាកដពីដំបូងដែលបានបង់សម្រាប់វត្ថុធាតុ គ្រឿងបន្លាស់ ឬ ផលិតផលនៃការមិនបានកំណត់ ពីប្រភពដើមនៅក្នុងទឹកដីនៃភាគីមួយដែលដំណើរការការងារ ឬកែច្នៃកំពុងប្រព្រឹត្តនៅទីនោះ។

(ឃ) វិធីសាស្ត្រការគណនាសមាសធាតុផ្សំតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា មានចែងនៅក្នុង បរិសិដ្ឋ ក។

វិធានទី ៥

វិធានបូកបន្ថែមនៃប្រភពដើម

លើកលែងតែអ្វីបានចែងផ្សេងពីនេះ ផលិតផលដែលបានបំពេញតាមលក្ខខណ្ឌប្រភពដើមដែលបានកំណត់នៅក្នុងវិធានទី ២ និងបានត្រូវប្រើប្រាស់នៅក្នុងដែនដីភាគីមួយ ជាវត្ថុធាតុសម្រាប់ផលិតផល

[១] ឬសំរាប់ការបានមកវិញនូវវត្ថុធាតុដើម។ ប្រតិបត្តិការផលិតកម្ម និងកែច្នៃនឹងកប់បញ្ចូលនូវការកែច្នៃគ្រប់ ប្រ ភេទ, មិនត្រឹមតែឧស្សាហកម្ម ឬ វត្ថុគីមីប៉ុណ្ណោះទេ តែក៏រាប់បញ្ចូល អាជីវកម្មរ៉ែ, កសិកម្ម, សំណង់, អាជីវកម្មស្តុដែក, ឈាបនកិច្ច និងប្រតិបត្តិការប្រព្រឹត្តកម្ម ដេរចាក់ផងដែរ។

ដែលអាចត្រូវបានទទួលប្រព្រឹត្តកម្មអនុគ្រោះ នៅក្រោមកិច្ចព្រមព្រៀងនេះនឹងត្រូវបានចាត់ទុកជាផលិតផល មានប្រភពដើមនៅក្នុងភាគីនោះដែលដំណើរការការងារ ឬ ការកែច្នៃនៃផលិតផលនេះបានផលិតនៅទីនោះ។

វិធានទី ៦

វិធាននៃផលិតផលដោយឡែក

ថ្វីបើមានបទប្បញ្ញត្តិក្នុងវិធានទី ៤ ក្តីផលិតផលដែលបំពេញតាមវិធានផលិតផលដោយឡែកនឹងត្រូវបានចាត់ទុកថាមានប្រភពដើមមកពីភាគីនោះ ដែលដំណើរការការងារ ឬ ការកែច្នៃនៃផលិតផលបានធ្វើនៅទីនោះ។ បញ្ជីនៃវិធានផលិតផលដោយឡែកនឹងត្រូវបានបន្ថែមនៅក្នុងឧបសម្ព័ន្ធ ខ។

វិធានទី ៧

ដំណើរការកែច្នៃ និងប្រតិបត្តិការអប្បបរមា

(ក) ថ្វីបើមានបទប្បញ្ញត្តិណាមួយនៅក្នុងឧបសម្ព័ន្ធនេះ ផលិតផលមួយមិនត្រូវបានចាត់ទុកមានប្រភពដើមនៅក្នុងភាគីមួយ លើសិនប្រតិបត្តិការដូចតទៅត្រូវបានទទួលធ្វើដាច់ដោយឡែកពីគ្នាដោយខ្លួនឯង ឬក្នុងការផ្សំនៅក្នុងទឹកដីរបស់ភាគីនោះ៖

(១) ប្រតិបត្តិការដើម្បីធានា ការបង្ការនៃផលិតផលនៅក្នុងលក្ខណៈសម្បត្តិល្អនៅក្នុងរយៈពេលដឹកជញ្ជូន និងស្តុកទុក (ដូចជា ការសម្ងួត ការបង្កក ការរក្សាទុកនៅក្នុងទឹកប្រៃ ការបញ្ចូលខ្យល់ ការពង្រីក ការធ្វើឱ្យត្រជាក់ ការប្រលាក់អំបិលស៊ុលហ្វួរ ដោយអុកស៊ីត ឬសូលុស្យុងជាតិទឹកផ្សេងៗទៀត ការយកចេញនូវគ្រឿងបន្លាស់ ដែលងាយខូចខាត និងប្រតិបត្តិការឯទៀតៗស្រដៀងៗគ្នា)។

(២) ប្រតិបត្តិការសាមញ្ញរួមមានការបំបាត់ធូលី ការរែង ឬ ការដាក់សំណាញ់ ការចែក ការចាត់ជាក្រុម ការផ្ទុះផ្តង់ (រួមបញ្ចូលទាំង ការធ្វើការតុបតែងនៃរូបរាងនៃទំនិញ ទាំងនោះ) ការដុសលាង ការលាបពណ៌ និងការកាត់។

(៣) ការផ្លាស់ប្តូរនៃការវេចខ្ចប់ និងការបំបែក និងផ្សំផ្គុំសម្រាប់ការបញ្ជូនទំនិញ។

(៤) ការកាត់ជាលក្ខណៈសាមញ្ញ ការហាន់ជាចំណិត វេចខ្ចប់ឡើងវិញ ឬ ការបង្ក្រុកទៅក្នុងដបធំ ដបតូច កាបូបប្រអប់ ការជូសជុលនៅលើក្រដាសរឹង និងប្រតិបត្តិការវេចខ្ចប់សាមញ្ញឯទៀតៗ។

(៥) ការបិទភ្ជាប់ផ្លាកសញ្ញា ឃីហោ ឬ ការសំគាល់សញ្ញាផ្សេងៗទៀតនៅលើផលិតផល ឬ នៅលើកញ្ចប់។

(៦) ការច្របល់បញ្ចូលគ្នាជាសាមញ្ញ នៃជលិតផលមិនដឹងថាប្រភេទទំនិញនោះដូចគ្នា ឬ ខុសគ្នា ដែលសមាសភាគមួយ ឬច្រើននៃល្បាយមិនប្រឈមលក្ខខណ្ឌដែលស្ថិតនៅក្រោមឧបសម្ព័ន្ធនេះ ដែលអាចធ្វើឱ្យជលិតផលទាំងនោះត្រូវបានពិចារណាជាជលិតផលមានប្រភពដើម។

(៧) ការតម្លើងជាសាមញ្ញនៃគ្រឿងបន្លាស់របស់ជលិតផល ដើម្បីបង្កើតទៅជាជលិតផលពេញលេញមួយ។

(៨) ការរុះរើចេញ។

(៩) ការសម្លាប់ដែលមានន័យថា ការសម្លាប់សត្វតែប៉ុណ្ណោះ។ និង

(១០) វត្ថុដែលគ្រាន់តែលាយទឹក ឬ សារធាតុផ្សេងទៀត ដែលមិនធ្វើឱ្យផ្លាស់ប្តូរចរិតលក្ខណៈនៃជលិតផល។

(ខ) សម្រាប់វាយនភ័ណ្ឌ និងជលិតផលវាយនភ័ណ្ឌបានចុះបញ្ជីក្នុងបរិសិដ្ឋ គ ទំនិញ ឬ វត្ថុធាតុមួយនឹងមិនត្រូវបានចាត់ទុកថា មានប្រភពដើមនៅក្នុងភាគីមួយដោយគ្រាន់តែទទួលរងនូវប្រតិបត្តិការណាមួយដូចតទៅ:

(១) ប្រតិបត្តិការបន្សំសាមញ្ញ ចិទដាក់ស្លាក ការសង្កត់ ការសំអាត ឬ សំងូត ឬ ប្រតិបត្តិការវេចខ្ចប់ ឬ ការបន្សំនៃវត្ថុទាំងនោះ។

(២) ការកាត់កំណាត់សំពត់តាមបណ្តោយ ឬ ទទឹង និងការដេរជាប់ ការដេរផ្សេរផ្សេរដែលអាចស្គាល់ថាជាការទុកសំរុងសម្រាប់ការប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្មដោយឡែក។

(៣) គ្រឿងតុបតែង និង/ឬ ការភ្ជាប់ទាំងអស់ដោយការដេរ ការរុំព័ទ្ធ ការភ្ជាប់ ការចងផ្គុំ គ្រឿងបន្លាប់បន្សំ ដូចជា ចង រុំ កិបគ្រាប់ ចងរឹត ព័ទ្ធជុំវិញ និងចោះប្រហោងតូចៗ។

(៤) ប្រតិបត្តិការសម្រេចម្តង ឬ ច្រើនដងលើសសៃអំបោះ កំណាត់សំពត់ ឬវាយនភ័ណ្ឌផ្សេងៗទៀតដូចជា ការធ្វើឱ្យទៅជាស ការជ្រលក់ ការពង្រួញ ការធ្វើឱ្យរលើប ឬ ប្រតិបត្តិការប្រហាក់ប្រហែល។ ឬ

(៥) ការជ្រលក់ពណ៌ ឬ បោះពុម្ពពណ៌ក្រណាត់សំពត់ ឬ សសៃអំបោះ។

វិធានទី ៨

ការបញ្ជូនទំនិញទៅត្រង់

ខាងក្រោមនេះ ត្រូវបានចាត់ទុកជាការបញ្ជូនទំនិញដោយត្រង់ពីភាគីនាំចេញទៅឲ្យភាគីនាំចូល :

- ទំនិញដែលបានដឹកជញ្ជូនឆ្លងកាត់ទឹកដី នៃភាគីតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌាណា

ជំពូក ១៤

ការកែប្រែ និងការពិនិត្យឡើងវិញ

ឧបសម្ព័ន្ធនេះ និងនីតិវិធីបណ្តាក់ទុនប្រតិបត្តិការអាចត្រូវធ្វើការពិនិត្យឡើងវិញ និងធ្វើការកែប្រែនៅពេលចាំបាច់ផ្អែកលើសំណើរបស់ភាគីម្ខាង និងដែលអាចមានការយល់ព្រមពីគណៈកម្មាធិការរួម។

បរិសិដ្ឋ ក

វិធីសាស្ត្រនៃការគណនាសមាសធាតុតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា

១. ថ្លៃ FOB នឹងត្រូវគណនាដូចតទៅ :

(ក) ថ្លៃ FOB = ថ្លៃនៅរោងចក្រ + ថ្លៃដើមផ្សេងៗ

(ខ) ថ្លៃដើមផ្សេងៗ នៅក្នុងការគណនាថ្លៃ FOB ត្រូវសំដៅទៅលើថ្លៃដើមបានកើតឡើងក្នុងទឹកន្លែងផលិតស្ថិតក្នុងនាវាសម្រាប់ការនាំចេញ រាប់បញ្ចូលទាំងប៉ុន្តែពុំមានការកំរិតដល់ថ្លៃដឹកជញ្ជូនក្នុងស្រុក ការដាក់ទុក និងការរៀបចំទំនិញបញ្ចូលឃ្លាំង ការប្រើប្រាស់កំពង់ផែ ថ្លៃឈ្នួលឈ្នួញកណ្តាល ថ្លៃសេវាកម្ម។ ល។

២. រូបមន្តសម្រាប់គណនា ថ្លៃនៅរោងចក្រ ៖

(ក) ថ្លៃនៅរោងចក្រ = ថ្លៃដើមផលិតកម្ម + ប្រាក់ចំណេញ។

(ខ) រូបមន្តសម្រាប់ការគណនា ថ្លៃដើមផលិតកម្ម។

១. ថ្លៃដើមផលិតកម្ម = ថ្លៃដើមវត្ថុធាតុដើម + ថ្លៃដើមពលកម្ម + ថ្លៃដើមចំណាយផ្សេងៗ។

២. វត្ថុធាតុដើម រួមមាន :
- ថ្លៃដើមវត្ថុធាតុដើម។
- ថ្លៃដឹកជញ្ជូន និងធានារ៉ាប់រង។

៣. ថ្លៃដើមពលកម្ម រួមមាន :
- ប្រាក់ខែ។
- លាភសការៈ ឬ ប្រាក់រង្វាន់។
- ប្រាក់បំណាច់ចំពោះនិយោជិកផ្សេងទៀតដែលរួមដំណើរការផលិតកម្ម។

៤. ថ្លៃដើមចំណាយផ្សេងៗ រាប់បញ្ចូលទាំង តែពុំបានកំណត់ដល់:
- មុខទំនិញអចលនទ្រព្យ រួមជាមួយដំណើរការផលិតកម្ម (ធានារ៉ាប់រង កិច្ចសន្យា និងការជួលរោងចក្រ ការរំលោះអាគារ ការជួសជុល និងការថែទាំ ពន្ធ ការប្រាក់លើការខ្ចី)។
- កិច្ចសន្យា និងការបង់ការប្រាក់សម្រាប់រោងចក្រ និងឧបករណ៍សម្ភារៈ។
- សន្តិសុខរោងចក្រ។
- ធានារ៉ាប់រង (រោងចក្រឧបករណ៍ និងសម្ភារៈបានប្រើប្រាស់នៅក្នុងផលិតកម្មទំនិញ)។

• ឧបករណ៍ និងសេវាកម្មផ្គត់ផ្គង់ (ថាមពលអគ្គីសនី ទឹក និងសេវាកម្មផ្គត់ផ្គង់ផ្សេងៗទៀតដែលអាចកំណត់បានដោយផ្ទាល់ដល់ផលិតកម្មទំនិញ)។

• ការស្រាវជ្រាវ ការអភិវឌ្ឍ គម្រោងការ និងសិក្ខាកម្ម។

• ពុម្ព ការចាក់ពុម្ព តារតុបតែងលំអរ និងការរំលោះ ការថែទាំ និងជួសជុល រោងចក្រ និងឧបករណ៍សម្ភារៈ។

• កម្រៃ ឬ អាជ្ញាប័ណ្ណ (គ្រឿងម៉ាស៊ីនដែលទទួលបានប៉ាតង់ ឬ ដំណើរការបានប្រើប្រាស់នៅក្នុងផលិតកម្មទំនិញ ឬ សិទ្ធិកាន់កាប់ផលិតកម្មទំនិញ)។

• អធិការកិច្ច និងការសាកល្បងវត្ថុធាតុ និងទំនិញ។

• ការស្តុក និងការប្រើប្រាស់នៅក្នុងរោងចក្រ។

• ការចែកចាយនៃកាកសំណល់កែច្នៃឡើងវិញ។

• ថ្លៃដើមវត្ថុធាតុនៅក្នុងការគណនាតម្លៃវត្ថុធាតុដើម ពោលគឺថ្លៃកំពង់ផែ និងថ្លៃត្រួតពិនិត្យ និងពន្ធនាំចូលដែលទទួលឧុសត្រូវនូវសមាសភាគដែលត្រូវបង់ពន្ធគយ។

បរិសិដ្ឋ ខ

ផលិតផលវិចារដោយឡែក

បរិសិដ្ឋ គ

បញ្ជីផលិតផលរួម នៃផលិតផលសាយនតណ្ឌ និងខ្សាយនតណ្ឌ

ក. ក្រណាត់ត្បាញ និងអំបោះស្រូត (Fibres and Yarn)

លេខ	ប្រព័ន្ធសុខដុម្ពនីយកម្ម ឆ្នាំ ២០០២	បរិយាយមុខទំនិញ	Description of Goods
១	៥០០៤.០០	អំបោះសូត្រ ក្រៅពីអំបោះដែលបានពីកំទេចសូត្រ ដែលមិនមែនសំរាប់ លក់រាយ	Silk yarn (other than yarn spun from silk waste) not put up for retail sale.
២	៥០០៥.០០	អំបោះនៃកំទេចសូត្រ ដែលមិនមែនលក់រាយ	Yarn spun from silk waste, not put up for retail sale.
៣	៥០០៦.០០	អំបោះសូត្រឬ កំទេចសូត្រ សំរាប់លក់រាយ Messine (crin de Florence)	Silk yarn and yarn spun from silk waste, put up for retail sale; silk-worm gut.
៤	៥១០៥.១០	- ឡែនថ្លេច	- Carded wool
		- ឡែនល្អធិងឡែនដទៃទៀតដែលសិតរួច :	- Wool tops and other combed wool:
៥	៥១០៥.២១	- - ឡែនសិត ជាកំរងតាត់រតាយ	- - Combed wool in fragments
៦	៥១០៥.២៩	- - ផ្សេងទៀត	- - Other
		- ពីរោមសត្វសរសៃឆ្មារសិតធិងប្រែង ឬសិត	- Fine animal hair, carded or combed
៧	៥១០៥.៣១	- - ពីរោមពពែរ	- - Of Kasmir (cashmere) goats
៨	៥១០៥.៣៩	- - ផ្សេងទៀត	- - Other
៩	៥១០៥.៤០	- ពីរោមសត្វសរសៃដ៏សិតធិងប្រែង ឬសិត	- Coarse animal hair, carded or combed
		សរសៃឡែនថ្លេចមិនបានច្នៃខ្ចប់សំរាប់លក់រាយ	Yarn of carded wool, not put up for retail sale.
១០	៥១០៦.១០	- ដែលមានជាតិឡែន ៨៥% ឬច្រើនជាង នៃទំងន់អំបោះ	- Containing 85 % or more by weight of wool
១១	៥១០៦.២០	- ដែលមានជាតិឡែនតិចជាង ៨៥% នៃទំងន់អំបោះ	- Containing less than 85 % by weight of wool
		សរសៃឡែនសិតមិនទាន់ច្នៃខ្ចប់សំរាប់លក់រាយ	Yarn of combed wool, not put up for retail sale.
១២	៥១០៧.១០	- ដែលមានជាតិឡែន៨៥% ឬច្រើនជាង នៃទំងន់អំបោះ	- Containing 85 % or more by weight of wool
១៣	៥១០៧.២០	- ដែលមានជាតិឡែនតិចជាង ៨៥% នៃទំងន់អំបោះ	- Containing less than 85 % by weight of wool
១៤	៥១០៨.១០	- សិតធិងប្រែង	- Carded
១៥	៥១០៨.២០	- សិត	- Combed
		សរសៃអំបោះពីឡែន ឬពីរោមសត្វសរសៃឆ្មារច្នៃខ្ចប់សំរាប់លក់រាយ	Yarn of wool or of fine animal hair, put up for retail sale.
១៦	៥១០៩.១០	- ដែលមានជាតិឡែនឬរោមសត្វសរសៃឆ្មារ ៨៥% ឬច្រើនជាង នៃទំងន់អំបោះ	- Containing 85 % or more by weight of wool or of fine animal hair
១៧	៥១០៩.៩០	- ផ្សេងទៀត	- Other
១៨	៥១១០.០០	អំបោះពីរោមសត្វសរសៃធំឬសក់សេះ រួមមានសរសៃសក់សេះសំរាប់គូរប៊ោះ ទោះជាមិនច្នៃខ្ចប់លក់រាយក៏ដោយ ។	Yarn of coarse animal hair or of horsehair (including gimped horsehair yarn), whether or not put up for retail sale.
		ក្រណាត់ត្បាញពីឡែនឬពីក្រណាត់រោមសត្វសរសៃឆ្មារដែលសិតធិងប្រែង	Woven fabrics of carded wool or of carded fine animal hair.
		- ដែលមានជាតិឡែនឬរោមសត្វសរសៃឆ្មារ៨៥% ឬច្រើនជាង នៃទំងន់អំបោះ :	- Containing 85% or more by weight of wool or of fine animal hair :
១៩	៥២០៤.១១	- - ដែលមានជាតិកប្បាសយ៉ាងតិច៨៥% នៃទំងន់អំបោះ	- - Containing 85 % or more by weight of cotton
២០	៥២០៤.១៩	- - ផ្សេងទៀត	- - Other
២១	៥២០៤.២០	- ខ្ចប់សំរាប់លក់រាយ	- Put up for retail sale
		ខ្សែអំបោះអំពីកប្បាស (ក្រៅពីចេសដេរ) ដែលមានជាតិកប្បាសយ៉ាងតិច ៨៥% នៃទម្ងន់អំបោះមិនទាន់ខ្ចប់សំរាប់លក់រាយ ។	Cotton yarn (other than sewing thread),containing 85 % or more by weight of cotton, not put up for retail sale.

		- សរសៃអំបោះមួយ អំពីអំបោះមិនទាន់សិត :	- Single yarn, of uncombed fibres:
២៥	៥២០៥.១១	- - ខ្នាត ៧១៤.២៩ ដេស៊ីតេច ឬលើស (មិនលើស ១៤ លេខម៉ែត្រ)	- - Measuring 714.29 decitex or more (not exceeding 14 metric number)
២៦	៥២០៥.១២	- - ខ្នាតតូចជាង ៧១៤.២៩ ដេស៊ីតេច ប៉ុន្តែមិនតូចជាង ២៣២.៥៦ ដេស៊ីតេច (លើសពី ១៤ លេខម៉ែត្រ ប៉ុន្តែមិនលើស ៤៣ លេខម៉ែត្រ)	- - Measuring less than 714.29 decitex but not less than 232.56 decitex (exceeding 14 metric number but not exceeding 43 metric number)
២៧	៥២០៥.១៣	- - ខ្នាតតូចជាង ២៣២.៥៦ ដេស៊ីតេច ប៉ុន្តែមិនតូចជាង ១៩២.៣១ ដេស៊ីតេច (លើសពី ៤៣ លេខម៉ែត្រប៉ុន្តែមិនលើសពី ៥២ លេខម៉ែត្រ) ។	- - Measuring less than 232.56 decitex but not less than 192.31 decitex (exceeding 43 metric number but not exceeding 52 metric number)
២៨	៥២០៥.១៤	- - ខ្នាតតូចជាង ១៩២.៣១ ប៉ុន្តែមិនតូចជាង ១២៥ ដេស៊ីតេច (លើសពី ៥២ លេខម៉ែត្រ ប៉ុន្តែមិនលើស ៨០ លេខម៉ែត្រ)	- - Measuring less than 192.31 decitex but not less than 125 decitex (exceeding 52 metric number but not exceeding 80 metric number)
២៩	៥២០៥.១៥	- - ខ្នាតតូចជាង ១២៥ ដេស៊ីតេច (លើសពី ៨០ លេខម៉ែត្រ)	- - Measuring less than 125 decitex (exceeding 80 metric number)
		- សរសៃអំបោះមួយ នៃអំបោះសិក្ខូច :	- Single yarn, of combed fibres :
៣៧	៥២០៥.២១	- -ខ្នាត ៧១៤.២៩ ដេចិតរេ ឬលើស (មិនលើសពី ១៤ លេខម៉ែត្រ)	- - Measuring 714.29 decitex or more (not exceeding 14 metric number)
៣៨	៥២០៥.២២	- - ខ្នាតតូចជាង ៧១៤.២៩ decitex ប៉ុន្តែមិនតូចជាង ២៣២.៥៦ decitex (លើសពី ១៤ លេខម៉ែត្រ ប៉ុន្តែមិនលើស ៤៣ លេខម៉ែត្រ) ។	- - Measuring less than 714.29 decitex but not less than 232.56 decitex (exceeding 14 metric number but not exceeding 43 metric number)
៣៩	៥២០៥.២៣	- - ខ្នាតតូចជាង ២៣២.៥៦ decitex ប៉ុន្តែមិនតូចជាង ១៩២.៣១ decitex (លើសពី ៤៣ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៥២ លេខម៉ែត្រ) ។	- - Measuring less than 232.56 decitex but not less than 192.31 decitex (exceeding 43 metric number but not exceeding 52 metric number)
៤០	៥២០៥.២៤	- - ខ្នាតតូចជាង ១៩២.៣១ decitex ប៉ុន្តែមិនតូចជាង ១២៥ decitex (លើសពី ៥២ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៨0 លេខម៉ែត្រ)	- - Measuring less than 192.31 decitex but not less than 125 decitex (exceeding 52 metric number but not exceeding 80 metric number)
៤១	៥២០៥.២៦	- - ខ្នាតតូចជាង ១២៥ decitex ប៉ុន្តែមិនតូចជាង ១០៦.៣៨ decitex (លើសពី ៨០ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៩៤ លេខម៉ែត្រ) ។	- - Measuring less than 125 decitex but not less than 106.38 decitex (exceeding 80 metric number but not exceeding 94 metric number)
៤២	៥២០៥.២៧	- -ខ្នាតតូចជាង ១០៦.៣៨ decitexប៉ុន្តែមិនតូចជាង ៨៣.៣៣ decitex (លើសពី ៩៤ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ១២០ លេខម៉ែត្រ) ។	- - Measuring less than 106.38 decitex but not less than 83.33 decitex (exceeding 94 metric number but not exceeding 120 metric number)
៤៣	៥២០៥.២៨	- -ខ្នាតតូចជាង ៨៣.៣៣ decitex (លើសពី ១២០ លេខម៉ែត្រ)	- - Measuring less than 83.33 decitex (exceeding 120 metric number)
		- អំបោះវេញពីសរសៃអំបោះពួរមិនទាន់សិត :	- Multiple (folded) or cabled yarn, of uncombed fibres:
៤៤	៥២០៥.៣១	- -ខ្នាតក្នុងសរសៃអំបោះមួយ ៧១៤.២៩ decitex ឬលើស (មិនលើពី ១៤ លេខម៉ែត្រ អំបោះមួយសរសៃ) ។	- - Measuring per single yarn 714.29 decitex or more (not exceeding 14 metric number per single yarn)
៤៥	៥២០៥.៣២	- -ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ៧១៤.២៩ decitex ប៉ុន្តែមិនតូចជាង ២៣២.៥៦ decitex (លើពី ១៤ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៤៣ លេខម៉ែត្រ ក្នុងអំបោះមួយសរសៃ) ។ ៦ ៨០	- - Measuring per single yarn less than 714.29 decitex but not less than 232.56 decitex (exceeding 14 metric number but not exceeding 43 metric number per single yarn)
៤៦	៥២០៥.៣៣	- -ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ២៣២.៥៦ decitex ប៉ុន្តែមិនតូចជាង ១៩២.៣១ decitex (លើពី៤៣លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៥២ លេខម៉ែត្រ ក្នុងអំបោះមួយសរសៃ) ។	- - Measuring per single yarn less than 232.56 decitex but not less than 192.31decitex (exceeding 43 metric number but not exceeding 52 metric number per single yarn)
៤៧	៥២០៥.៣៤	- -ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ១៩២.៣១ decitex ប៉ុន្តែមិនតូចជាង ១២៥ decitex (លើពី ៥២ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៨0 លេខម៉ែត្រក្នុងអំបោះមួយសរសៃ) ។	- - Measuring per single yarn less than 192.31 decitex but not less than 125 decitex (exceeding 52 metric number but not exceeding 80 metric number per single yarn)

៣៨	៥២០៥.៣៥	- -ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ១២៥ decitex (លើសពី ៨០ លេខម៉ែត្រ)អំបោះមួយសរសៃ) ។	- - Measuring per single yarn less than 125 decitex (exceeding 80 metric number per single yarn)
		- អំបោះច្រើនសរសៃវេញជាព្យួរសិតូច :	- Multiple (folded) or cabled yarn, of combed fibres:
៣៩	៥២០៥.៤១	- -ខ្នាតក្នុងសរសៃអំបោះមួយ ៧១៤.២៩ decitex ឬលើស មិនលើសពី ១៤ លេខម៉ែត្រ អំបោះមួយសរសៃ)	- - Measuring per single yarn 714.29 decitex or more (not exceeding 14 metric number per single yarn)
៤០	៥២០៥.៤២	- - ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ៧១៤.២៩ decitexប៉ុន្តែមិនតូចជាង២៣២.៥៦ decitex(លើសពី ១៤លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៤៣ លេខម៉ែត្រក្នុងអំបោះមួយសរសៃ)	- - Measuring per single yarn less than 714.29 decitex but not less than 232.56 decitex (exceeding 14 metric number but not exceeding 43 metric number per single yarn)
៤១	៥២០៥.៤៣	- - ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ២៣២.៥៦ decitexប៉ុន្តែមិនតូចជាង១៩២.៣១ decitex (លើសពី ៤៣ លេខម៉ែត្រ) ប៉ុន្តែមិនលើសពី ៥២ លេខម៉ែត្រក្នុងអំបោះមួយសរសៃ)	- - Measuring per single yarn less than 232.56 decitex but not less than 192.31decitex (exceeding 43 metric number but not exceeding 52 metric number per single yarn)
៤២	៥២០៥.៤៤	- - ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ១៩២.៣១ decitex ប៉ុន្តែមិនតូចជាង ១២៥ decitex (លើសពី៥២ លេខម៉ែត្រ ប៉ុន្តែមិនលើសពី៨០លេខម៉ែត្រក្នុងអំបោះមួយសរសៃ) ។	- - Measuring per single yarn less than 192.31 decitex but not less than 125 decitex (exceeding 52 metric number but not exceeding 80 metric number per single yarn)
៤៣	៥២០៥.៤៦	- - ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ១២៥ decitex ប៉ុន្តែមិនតូចជាង ១០៦.៣៨ decitex (លើសពី ៨០ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៩៤ លេខម៉ែត្រ ក្នុងអំបោះមួយសរសៃ) ។	- - Measuring per single yarn less than 125 decitex but not less than 106.38 decitex (exceeding 80 metric number but not exceeding 94 metric number per single yarn)
៤៤	៥២០៥.៤៧	- - ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ១០៦.៣៨ decitex ប៉ុន្តែមិនតូចជាង ៨៣.៣៣ decitex (លើសពី ៩៤ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ១២០ លេខម៉ែត្រក្នុងអំបោះមួយសរសៃ) ។	- - Measuring per single yarn less than 106.38 decitex but not less than 83.33 decitex (exceeding 94 metric number but not exceeding 120 metric number per single yarn)
៤៥	៥២០៥.៤៨	- - ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ៨៣.៣៣ decitex (លើសពី ១២០លេខម៉ែត្រអំបោះមួយសរសៃ) ។	- - Measuring per single yarn less than 83.33 decitex (exceeding 120 metric number per single yarn)
		ខ្សែអំបោះអំពីកប្បាស ក្រៅពីអំបោះដេរ ដែលមានជាតិកប្បាសតិចជាង ៨៥% នៃទម្ងន់អំបោះមិនទាន់ខ្ចប់សំរាប់លក់រាយ ។	Cotton yarn (other than sewing thread), containing less than 85 % by weight of cotton, not put up for retail sale.
		- សរសៃអំបោះមួយធ្វើពីអំបោះមិនទាន់សិត :	- Single yarn, of uncombed fibres :
៤៦	៥២០៦.១១	- - ខ្នាត ៧១៤.២៩ decitex ឬលើស (មិនលើសពី ១៤ លេខម៉ែត្រ)	- - Measuring 714.29 decitex or more (not exceeding 14 metric number)
៤៧	៥២០៦.១២	- - ខ្នាតតូចជាង ៧១៤.២៩ decitex ប៉ុន្តែមិនតូចជាង ២៣២.៥៦ decitex (លើសពី ១៤ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៤៣ លេខម៉ែត្រ) ។	- - Measuring less than 714.29 decitex but not less than 232.56 decitex (exceeding 14 metric number but not exceeding 43 metric number)
៤៨	៥២០៦.១៣	- - ខ្នាតតូចជាង ២៣២.៥៦ decitex ប៉ុន្តែមិនតូចជាង ១៩២.៣១ decitex (លើសពី ៤៣ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៥២ លេខម៉ែត្រ) ។	- - Measuring less than 232.56 decitex but not less than 192.31 decitex (exceeding 43 metric number but not exceeding 52 metric number)
៤៩	៥២០៦.១៤	- - ខ្នាតតូចជាង ១៩២.៣១ decitex ប៉ុន្តែមិនតូចជាង ១២៥ decitex (លើស ពី ៥២ លេខម៉ែត្រប៉ុន្តែមិនលើសពី ៨០ លេខម៉ែត្រ) ។	- - Measuring less than 192.31 decitex but not less than 125 decitex (exceeding 52 metric number but not exceeding 80 metric number)
៥០	៥២០៦.១៥	- - ខ្នាតក្នុងសរសៃអំបោះមួយតូចជាង ១២៥ decitex (លើសពី៨០លេខម៉ែត្រ)	- - Measuring less than 125 decitex (exceeding 80 metric number)
		- អំបោះ សរសៃអំបោះសិតូច :	- Single yarn, of combed fibres :
៥១	៥២០៦.២១	- - ខ្នាតសរសៃអំបោះមួយសរសៃ ៧១៤.២៩ decitex ឬលើស (មិនលើសពី ១៤ លេខម៉ែត្រ) ។	- - Measuring 714.29 decitex or more (not exceeding 14 metric number)
៥២	៥២០៦.២២	- - ខ្នាតសរសៃអំបោះមួយសរសៃតូចជាង ៧១៤.២៩ decitex ប៉ុន្តែមិនតូចជាង ២៣២.៥៦ decitex (មិនលើសពី ១៤ លេខម៉ែត្រប៉ុន្តែមិនលើសពី ៤៣ លេខម៉ែត្រ) ។	- - Measuring less than 714.29 decitex but not less than 232.56 decitex (exceeding 14 metric number but not exceeding 43 metric number)

៥៣	៥២០៦.២៣	- - ខ្នាតក្នុងអំបោះមួយសរសៃតូចជាង ២៣២.៥៦ decitex ប៉ុន្តែមិនតូចជាង ១៩២.៣១ decitex (លើសពី ៤៣ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៥២ លេខម៉ែត្រ)	- - Measuring less than 232.56 decitex but not less than 192.31 decitex (exceeding 43 metric number but not exceeding 52 metric number)
៥៤	៥២០៦.២៤	- - ខ្នាតក្នុងអំបោះមួយសរសៃតូចជាង ១៩២.៣១ decitex ប៉ុន្តែមិនតូចជាង១២៥ decitex (លើសពី ៥២ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៨០ លេខម៉ែត្រ) ។	- - Measuring less than 192.31 decitex but not less than 125 decitex (exceeding 52 metric number but not exceeding 80 metric number)
៥៥	៥២០៦.២៥	- - ខ្នាតក្នុងអំបោះមួយសរសៃតូចជាង ១២៥ decitex (លើសពី៨០ លេខម៉ែត្រ)	- - Measuring less than 125 decitex (exceeding 80 metric number)
		- អំបោះវេញច្រើនសរសៃមិនទាន់សិត :	- Multiple (folded) or cabled yarn, of uncombed fibres:
៥៦	៥២០៦.៣១	- - ខ្នាតអំបោះមួយសរសៃ ៧១៤.២៩ decitex ឬលើស (មិនលើសពី ១៤លេខម៉ែត្រក្នុងអំបោះមួយសរសៃ) ។	- - Measuring per single yarn 714.29 decitex or more (not exceeding 14 metric number per single yarn)
៥៧	៥២០៦.៣២	- - ខ្នាតក្នុងអំបោះមួយសរសៃតូចជាង ៧១៤.២៩ decitex ប៉ុន្តែមិនតូចជាង២៣២.៥៦ decitex (មិនលើសពី១៤លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៤៣ លេខម៉ែត្រ ក្នុងអំបោះមួយសរសៃ) ។	- - Measuring per single yarn less than 714.29 decitex but not less than 232.56 decitex (exceeding 14 metric number but not exceeding 43 metric number per single yarn)
៥៨	៥២០៦.៣៣	- - ខ្នាតក្នុងអំបោះមួយសរសៃតូចជាង ២៣២.៥៦ decitex ប៉ុន្តែមិនតូចជាង ១៩២.៣១ decitex (លើសពី ៤៣ លេខម៉ែត្រ ប៉ុន្តែមិនលើសពី ៥២ លេខម៉ែត្រក្នុងអំបោះមួយសរសៃ) ។	- - Measuring per single yarn less than 232.56 decitex but not less than192.31 decitex (exceeding 43 metric number but not exceeding 52 metric number per single yarn)
